# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា សូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---

| *ផ្នែកអក្សរសាស្ត្រ* | *បញ្ជីរឿង* | *ទំព័រ* |
|---|---|---|
| មហា ខម-ណាគ្រី | កវីធម្មាសិត ........................ | ៣២១ |
| លោក ជា-ជួន | ការធ្វើសំពត់ហូល, ផាមួង, និងសារុង....... | ៣២៤ |
| លោក ភិយ-ប៊ុក ក្រមការ | សុភាសិតខ្មែរភាគទី ២ (តមក)............ | ៣៣១ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ស័ព្ទបារាំងប្រែជាខ្មែររបស់គណៈកម្មការវប្បធម៌ (តមក).............................. | ៣៣៥ |
| — | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌៀ (តមក) .. | ៣៤៥ |
| អ្នកនាងញ៉ាព្រះឃ្លាំងខង | រឿងភោគកុលកុមារ ពាក្យកាព្យ (តមក) ..... | ៣៥៦ |
| *ផ្នែកសាសនា* | | |
| លោក ភិយ-ប៊ុក ក្រមការ | ពុទ្ធអាស៊ីទ្វីប (តមក) ................... | ៣៦៣ |
| មហា ខម-ណាគ្រី | និរយកថា ............................ | ៣៧៨ |
| *កំណត់និងប្រវត្តិការណ៍* | | |
| ក្រសួងធម្មការ | បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) ... | ៣៨៨ |
| លោក ភិយ-ប៊ុក ក្រមការ | កំណត់ស្ដីពីរឿងស្ថាបនាវិទ្យាស្ថានមួយសម្រាប់ សិក្សាភាសាខ្មែរ តណ្ឌៀ នៅភ្នំពេញ ...... | ៣៩៨ |

---

ឆ្នាំទី ២១ — លេខ ១០ ខែតុលា ឆ្នាំ ១៩៤៩ — ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ១

គាថាជម្នាសិត

# មហានិម-ណាគ្រី

ឃុំស្វាយពោធិ៍ ស្រុកសង្កែ ខេត្តបាត់ដំបង ប្រែរៀបរៀង

អារោគ្យបរមា លាភា សន្តុដ្ឋី បរមំ ធនំ
វិស្សាសា បរមា ញាតី និព្វានំ បរមំ សុខំ ។

ការនិរាសប្រាសប្រាត់ឃ្លាតចាករោគ ចាត់ជាជោគលាភលន់ពន់ពេកក្រៃ
ការមានរោគរុំរឹតឈឺរ៉ាំរ៉ៃ តែងជាភ័យចង្រៃនៃពួកជន ។
ការសន្តោសត្រេកអរតាមមានបាន ជាហេតុឲ្យកើតសាន្តសុខលើសលន់
ឲ្យចំរើនកើនប្រយោជន៍បច្ចុប្បន្ន ឲ្យសម្បូណ៌សម្បត្តិធននានា ។
ជាមង្គលដ៏ឧត្តមសមឧត្តុង្គ ជារបស់នៅក្នុងភពភារា
អ្នកសន្តោសក្នុងសន្តានសព្វវេលា នឹងរួចទុក្ខទោសនានាជាមិនខាន ។
ឲ្យវិញ្ញូនាថាវរៈមិនថ្នាក់ចិត្ត ឲ្យប្រព្រឹត្តព្រះសទ្ធម្មមាំមួនបាន
ឲ្យសប្បាយទាំងកាយចិត្តឥតរំខាន ឲ្យក្សេមក្សាន្តបានសុខស្រួល
ជានិរន្តរ៍ ។

សេចក្តីល្មោភលោភល្មើសលើសចំនួន ខុសក្បួនជ្រុលជ្រួសហួសដើមទុន
ជាហេតុឲ្យកើតទុក្ខទោសទម្ងន់ ឲ្យក្តុកក្តន់ក្តៅក្តួលរំជួលចិត្ត ។
ឲ្យធ្វើបាបអំពើទាបភាពអាក្រក់ ឲ្យលួចឆក់ឆបោកទុច្ចរិត

ឲ្យក្រហាយក្រហល់ខ្វក់ខ្វល់ចិត្ត  ឲ្យប្រព្រឹត្តទុច្ចរិតឥតអៀនខ្មាស ។
ការស្គាល់ស្និទ្ធមេត្រីក្តីរាប់អាន  ហាក់ជាញាតិសន្តានពន់ពេកណាស់
ការរាប់អាននាំឲ្យមានមិត្តក្រៃក្រាស់ ការវិស្សាសល្អវិសាលគួរនិយម ។
អ្នកដទៃឲ្យប្រយោជន៍ទុកជាញាតិ  ញាតិបើឃ្លាតទុកជាជាតិជនក្រៅក្រុម
ការរាប់អានអាចធ្វើជនឲ្យជួបជុំ  គួរអប់រម្យការរាប់អានឲ្យមានណា ។
ព្រះនិព្វានជាឋានសុខសប្បាយក្រៃ ព្រះនិព្វានគ្មានទុក្ខភ័យក្ស័យតណ្ហា
ព្រះនិព្វានគ្មានកើតស្លាប់ក្នុងសង្សារ ព្រះនិព្វានគ្មានអាល័យថៃអាឡោះ ។
ព្រះនិព្វានសុខអនេកឯកអន័គ្ឃ  ព្រះនិព្វានគ្មានបំពាក់ទាក់ទើសសោះ
ព្រះនិព្វានគ្មានស្រណោកសោកស្រណោះ ព្រះនិព្វានអស់សម្រេក
ស្រេកឃ្លានហើយ ។
ព្រះនិព្វានជាទីនៅនៃអរហន្ត  ព្រះនិព្វានបុថុជ្ជនមិនឃើញឡើយ
ព្រះនិព្វានគ្មានជាតិជរាព្យាធិជាត្រើយ ព្រះនិព្វាននៅកន្តើយស្បើយ
ទុក្ខអើយ !!

## សុភាសិត

១ — នរជនទឹងធ្លាក់ចុះថោកទាប  ឬចំរើនខ្ពង់ខ្ពស់ឡើង ក៏ព្រោះកម្មរបស់ខ្លួនជាអ្នកបណ្ដាលឲ្យប្រព្រឹត្តទៅ,  ដូចបុគ្គលជីកស្រះក៏ត្រូវចុះទៅកាន់ទីទាប,  បុគ្គលកកំពែងក៏ត្រូវឡើងទៅកាន់ទីខ្ពស់ ។

២ – របស់ដែលកម្ទំនុកបំរុងមិនបាច់ឲ្យនរណាជួយថែរក្សា ក៏រមែងគង់វង់ឋិតនៅបាន, របស់ដែលកម្ទេចម្ចាយទម្លុះទោះបីនរណាជួយពិតក្សរក្សាយ៉ាងណាក៏ដោយ រមែងវិនាសទៅទាល់តែបាន ។

៣– ពាក្យសំដីដែលពោលដោយប្រពៃត្រឹមត្រូវ សូម្បីអ្នកនិយាយជាកូនក្មេងក៏គួរស្តាប់ចាប់យកជាខប្រតិបត្តិបាន កាលមិនឃើញពន្លឺព្រះអាទិត្យ ពន្លឺប្រទីបធម្មតានឹងប្រើឲ្យជាគុណប្រយោជន៍មិនបានទៅឬ? ។

៤ – សេះ, សស្ត្រាវុធ, សៀវភៅ, ពាក្យសំដី, ពិណ, ប្រុស, ស្រីនឹងក្មេងដែលនឹងប្រើបានល្អ ឬ មិនល្អក៏ស្រេចនឹងវិធីការរបស់អ្នកប្រើ ។

៥ – កាលឃើញសេចក្តីវិបត្តិធ្លាក់ដល់នរណា សូម្បីគេមិនអង្វរករពឹងពាក់ ក៏គួរកុលបុត្រអនុគ្រោះប្រាប់ឲ្យដឹងខ្លួន នេះឯងជាគុណសម្បត្តិរបស់អ្នកល្អទាំងឡាយ ។

៦ – អ្នកដែលក្រោធដោយមានហេតុផល កាលកំចាត់ហេតុផលដែលក្រោធនោះចោលហើយក៏ស្ងប់ដោយរហ័ស តែអ្នកដែលមានចិត្តក្រោធដោយប្រាសចាកហេតុផល នរណានឹងធ្វើយ៉ាងណា ទើបនឹងលួងលោមគេឲ្យត្រេកអរបាន? ។

៧ – នរៈណាមានប្រាជ្ញា នរៈនោះក៏មានកំឡាំង នរៈណាមិនមានប្រាជ្ញា នរៈនោះនឹងបានកំឡាំងមកអំពីទីណា? ចូរមើលរាជសីហ៍ដែលមានខ្លួនធំ ហើយក៏ចាញ់កង្កែបដែលមានខ្លួនតូច ។

# ការធ្វើសំពត់ហូល, ផាមួងនិងសារុង

របស់ ផា - ដួន ឃុំបឹងគ្រំ - ស្រុកល្វាឯម - ខេត្តកណ្ដាល

(រង្វាន់លេខ ៣)

••••••••

នៅស្រុកខ្មែរ មានរបរដម្បាញសំពត់, ផាមួង, ហូល, សារុង ព្រែលាត ជាដើម ។ របរនេះនៅស្រុកខ្មែរយើង មានច្រើនកន្លែងណាស់ មានស្រុកបាទី, ប្សារអំពៅ, កោះរះ, ថ្គរ, បឹងគ្រំ, ល្វាស, ព្រែកដែ, ព្រែកក្របជាដើម ។ ឯអ្នកប្រើនោះតែងស្លៀកពាក់សឹងគ្រប់គ្នាក្នុងស្រុកខ្មែរ ថែមទាំងមានកេរ្តិ៍ឈ្មោះល្បីទៅដល់ប្រទេសក្រៅផង ។

គ្រឿងទព្វសម្ភារៈរបរដម្បាញនេះ គឺកី, រហាត់, អាក់, អន្ទឹង, បំពង់, ឈើអន្ទួង, ត្រល់, ខ្នារ, ឈើពាក់ ។

មុនដំបូងយកសូត្រដាក់នឹងអាក់ អាក់នោះមានមេបញ្ឈរពីរកំពស់ ៣ តឹក ។ តួអាក់មានសណ្ឋានដូចដុំរទេះ មានមេសណ្ដូក ១ ទទឹង ១ តឹក បណ្ដោយ ៤ តឹក ដើម្បីឲ្យនឹង ។ លុះពាក់រួច គេប្រមូលស្រាវរើសមុខ គឺគេះក្រមរដែលគ្រើមៗចេញ រើសសរសៃតូច - ធំ កណ្ដាល ណាតូចដាក់ដោយតូច ធំដាក់ដោយធំ កណ្ដាលដាក់ដោយកណ្ដាល ។ រួចយកទៅដាក់រហាត់ខារដាក់បំពង់ ។

**រហាត់**— រហាត់នោះមានមេសណ្ដូក ១ ប្រវែង ៤ តឹក បន្ទា ៥ ហ៊ុន ទោល ៣ ហ៊ុន មេទទឹង ១ បន្ទាទោលដូចគ្នា ។ គេដាប់បញ្ចុះ

មេទាំងលើទៀត ។ ស្លាបរហាត់នោះធ្វើអំពីឫស្សី គេយកឫស្សីពីរសាច់បិតឲ្យសំប៉ែត ស្របចុង កណ្ដាលធំ ស្លាបរហាត់ទាំងអស់ ៨ គេដាក់ ៤ ម្ខាងៗ យកខ្សែផ្ដៅបិតឲ្យធ្នារប៉ុនគ្រាប់ត្រសក់យកមកបាក់រឹតឲ្យតឹងកោង ដាក់ក្ដៅឲ្យវិល ដាក់លើមេបញ្ឈរពីរនោះ ដើម្បីពាក់សូត្រខារដាក់បំពង់ ។

បំពង់គេកាត់ឫស្សី ១ សាច់ បណ្ដោយពីរតឹក ទំហំ ៥ ហ៊ុន មានរាងមូល រវៃវិលស្រាវពីរហាត់មកដាក់បំពង់ លុះរាវដាក់បំពង់រួចហើយយកទៅរវៃឲ្យខ្ចាញ់ ឬរវៃបញ្ចូលឲ្យត្រូបជាមុខពីរ ឬមុខបី រួចយកទៅពាក់ដាក់កុងឲ្យដឹងចំនួនសាច់សូត្របានប៉ុន្មានៗ រួចស្រាវយកទៅប្រមោក ។ ប្រមោកគឺគេយកទៅលាងទឹងទឹកក្បុងឲ្យជ្រះក្អែល ឲ្យស្អាត ទើបយកទៅជ្រលក់ល័ក្ត ។ ពេលជ្រលក់ត្រូវតម កុំឲ្យមានមនុស្សស្រីមានផ្ទៃពោះមកមើល តែមើលឃើញសូត្រនោះនឹងធ្លាក់មិនជិតល័ក្ត ។

វិធីតម — ពេលដែលរៀបជ្រលក់ល័ក្តត្រូវធ្វើបន្ទប់ ឬបិទបាំងហ៊ុំព័ទ្ធឲ្យជិត កុំឲ្យអ្នកដទៃមកជិត ពុំនោះសោតជ្រលក់ក្នុងផ្ទះក៏បាន ប៉ុន្តែហាមដាច់មិនឲ្យមនុស្សស្រីមានផ្ទៃពោះមើលឲ្យសោះ ។ បើជាម្ចាស់ខ្លួនមានផ្ទៃពោះវិញមិនជាការទាស់អ្វីទេ ។ ការជ្រលក់ល័ក្តមានពណ៌ផ្សេងៗ គឺពណ៌ក្រហម គេជ្រលក់ល័ក្តក្រហម ពណ៌ស្វាយ គេជ្រលក់ល័ក្តស្វាយ ពណ៌ខៀវ គេជ្រលក់ល័ក្តខៀវ ជ្រលក់ដាក់ក្នុងថ្លាង ស្មោរ

ជាមួយទឹងសាច់ជូរ ប្រយោជន៍ដើម្បីឲ្យចាំពណ៌កុំឲ្យហើរ ឬចេញល័ក្ត រួចយកទៅខារជាក់បំពង់យកទៅអន្ទង់ បំពង់នោះខារឲ្យបានចំនួន ៤០ ទើបអន្ទង់ ។

ឈើអន្ទង់ — ឈើអន្ទង់នោះ គេធ្វើមេពីរបន្ទះ ១ តឹក ទោល ៥ ហ៊ុន ប្រវែង ១ ម៉ែត្រ ជាប់ប្រហោងដាក់កូន ១៦ ម្ខាង ដូចជាធ្មេញរនាស់ដែរ មានឈើសណ្តាកដាក់ទល់ចំកណ្តាល កុំឲ្យទន់ឬជាបចុះ បានយកជើងម៉ា ឬ ត្បាល់ដាក់ទ្រចំកណ្តាលទៀត ។

ឈើពាក់ — ឈើពាក់នោះ យកដើមពីងពង់ឲ្យត្រង់ល្អ គេវៃដាក់ក្រវិលចំនួន ៤០ ក្រវិល ប្រវែង ១០ ម៉ែត្រ ចងឲ្យខ្ពស់ផុតក្បាល យកមុខសូត្រដែលនៅទឹងបំពង់មកស៊កក្នុងក្រវិលនោះ ទើបទាញយកមកចងទឹងកូនអន្ទង់ ដាក់ប្រែងយកទៅមួរ ។

ក្តារមួរ — ក្តារមួរបណ្តោយ ១ ម៉ែត្រ ២ តឹក ទោល ៥ ហ៊ុន មានមនុស្សពីរនាក់កាន់ចុងក្តារម្ខាងម្នាក់ មានពីរនាក់ទៀត កាន់ជាមអូសនាំមុខកុំឲ្យសូត្រជំពាក់ មានម្នាក់កាន់ចុងសូត្រដែលលានោះ ទាញឲ្យតឹង អ្នកមួរបេះតែមួរតាមអូសជាម អ្នកឈរទាញបេះតែទាញឲ្យតឹង លាម្តងចំនួន ១០ ម៉ែត្រ មួរដកបដល់អស់ ពីរនាក់ឈរកាន់ ទើបយកទៅចាក់ធ្មេញក្រដូបស៊កក្នុងធ្មេញឈើ ។

ធ្មេញឈើ — ធ្មេញឈើធ្វើពីឫស្សី យកឫស្សីពុះឲ្យធ្មារស្តើង ប្រវែង ១ តឹក យកទៅចងស្រែះទឹងខ្សែអំបោះមានសណ្ឋានដូចជាស្នូក

សិតថៃ ម្នាក់ចាក់ធ្មេញក្រដូប ម្នាក់ស៊កសរសៃសូត្រគ្រប់ចន្លោះធ្មេញ ហើយទើបថ្ករ ពេលដែលថ្ករនោះ គេយកទៅដាក់នឹងកីដែលសម្រាប់ត្បាញ ។

កីនោះមានគ្រឿងច្រើនយ៉ាង គឺមានមេសណ្ដូក ២ បណ្ដោយ ៥ ម៉ែត្រ បន្ទា ១ តឹក ភោល ៥ ហ៊ុន មានជើង ៤ មុខពីរ ក្រោយពីរ កំពស់ពីជំហីតឹក មានមេចម្រឹង ៤ កំពស់ ១ ម៉ែត្រ មានមេខាងលើ ៤ ទៀត ធ្វើជារនងឲ្យរឹង មានឈើ ១ ដាក់ទទឹងគេហៅថា "ក" សម្រាប់ចងព្យួរពីថ្ករមក មានឈ្នាន់ ២ ខាងក្រោមសម្រាប់ជាន់ឲ្យដង្កូវញែកហាសរសៃសូត្រអន្ទងឲ្យប្រហោង ដើម្បីបោះត្រល់ត្បាញ ។

ត្រល់ ត្រល់នោះគេធ្វើអំពីឈើមានចំនួន ១ តឹកកន្ទះ គេឈូសចុងដើមឲ្យស្រួចដូចជាមុខកប៉ាល់ ហើយគេលុកបំកណ្ដាល រួចគេយកដែកឆ័ត្រ ឬដែករឹងតែតូចល្មមទៅបញ្ចុះដាក់បណ្ដោយសាច់ត្រល់ ។

មានឈើទទឹងខាងចុង១មួលប៉ុនកដៃសម្រាប់ទាញរឹតពីក្ដារមូរឲ្យតឹង ។

ពេលត្បាញ គេខារសូត្រដាក់ខ្នារតូចប៉ុនចង្កឹះស៊កនឹងដែកដែលទៅក្នុងត្រល់ កាលណាបាក់ត្រល់គេជាន់ឈ្នាន់ឲ្យហា ទើបបោះត្រល់ទៅ បោះម្ដងរួចបាក់តទៅទៀត បាក់ទៅបាក់មកក្នុង ១ ថ្ងៃបាន ៥ តឹកយ៉ាងលឿន ។ គ្រឿងតម្បាញនេះ មានក្នុងគម្ពីរធម្មបទដ្ឋកថា ភាគ ៧ ទំព័រ ១៣ ខាងព្រះពុទ្ធសាសនា ។

មានសេចក្តីដំណាលថា មានកុលបុត្រម្នាក់នៅក្រុងសាវត្ថី ទៅបួសជាភិក្ខុ បាននាមបញ្ញត្តិថា "តិស្សត្ថេរ" ពេលក្រោយមកលោកបានសំពត់សាដក ១ សាច់ក្រាស់ចំនួន ៨ ហត្ថ ក៏យកមកផ្ញើទឹងប្អូនស្រីលោក ៗ ឯប្អូនស្រីនោះជាស្រីឈ្លាសក្នុងវិធីត្បាញ នាងក៏គិតថា បងអញមិនសមប្រើប្រើសំពត់ក្រាស់បែបនេះសោះ គិតហើយក៏យកសំពត់នោះទៅប្រៀកជាបំរៀកតូចៗ ហើយបុកឲ្យល្អិតយកមកវេចៗ ហើយការៗ ហើយថ្ករៗ ហើយអន្ទង់ៗ ហើយត្បាញ កើតបានជាសំពត់មានសាច់ម៉ដ្ឋប្រវែង ៩ ហត្ថ ។

សំពត់ហូល - របៀបធ្វើប្រដាប់ទាំងអស់ដូចគ្នានឹងសំពត់ផាមួងដែរ ឃើញប្លែកតែមានក្រឡាមានគោមតែប៉ុណ្ណោះ ។ ឯគ្រឿងផ្ទែលក់សូត្រខុសគ្នា សំពត់ហូលចង់គាតទើបបានគេផ្ទែលក់ជាក្រោយ ចង់គាតនោះយកស្រទបចេកណាំពាមកសកឲ្យស្តើងប៉ុនក្នុងដៃ យកមករុំសូត្រទុកឲ្យសល់ប៉ុន្មានដែលត្រូវការផ្ទែលក់ ធ្វើជាក្រឡា ជាក្រឡាគោម ។

សារុង - របៀបធ្វើដូចគ្នាទាំងអស់ ប្លែកតែក្រឡា គេអន្ទង់មានផ្កាស់ក្រឡាផ្សេង មានមេក្បួន ឬសខៅប៉ុណ្ណោះ ។

ព្រែលាត - ព្រែលាតនោះ របៀបធ្វើដូចខាងដើម គ្មានផ្ទែលក់ល័ក្តទេ គេធ្វើសូត្រសសុទ្ធ ។

១ — សេចក្ដីអធិប្បាយអំពីសំពត់ផាមួង — សំពត់ផាមួងមានពណ៌ ៥ យ៉ាង គឺពណ៌ស្វាយទ្រាំ ១ ខ្វាញ់ក្ដាម ១ ពណ៌មាស ១ ពណ៌ត្រួយលៀប ១ ពណ៌ស្លឹកចេក ១ ។ កាលណាគេអនួងស្វាយ គេចាក់ស្វាយទៅជាស្វាយទ្រាំ, អនួងក្រហមចាក់ក្រហមទៅជាពណ៌មាស, អនួងក្រហមចាក់លឿងទៅជាពណ៌ខ្វាញ់ក្ដាម, អនួងក្រហម ចាក់ខៀវទៅជាពណ៌ត្រួយលៀប អនួងខៀវ ចាក់ខៀវទៅជាពណ៌ត្រួយចេក ។

សេចក្ដីពន្យល់អំពីសូត្រ — កងសូត្រ ១ ម៉ឺ មានទម្ងន់ ២ តាលកន្លះ យកទៅធ្វើបានសំពត់ ២ ទាំងចាក់ទាំងអនួង កងសំពត់មួយ ៗ ប្រវែង ៣ ម៉ែត្រ ទទឹងធ្មេញឈើ ១ ម៉ែត្រ ក្រាស់ស្ដើងស្រេចតែអ្នកធ្វើ បើចង់ឲ្យក្រាស់គួបមុខពីរ គឺវៃសូត្របញ្ចូលពីរសរសៃទើបក្រាស់ បើចង់ឲ្យស្ដើងអនួង ១ សរសៃ ចាក់ ១ សរសៃ ។

២ — សេចក្ដីអធិប្បាយអំពីសំពត់ហូល — សំពត់ហូលមានក្រឡាច្រើនបែប គឺក្រឡាផ្កាយព្រឹក ផ្កាម្លុស ។ល។ កងសូត្រ ១ ម៉ឺធ្វើបានសំពត់ហូល ៨ ទាំងចាក់ទាំងអនួង បណ្ដោយ ១ ម៉ែត្រ ៩ តឹក ទទឹងធ្មេញឈើ ៨ តឹក ។

៣ — សេចក្ដីអធិប្បាយអំពីសារុង — សារុងគេជ្រលក់សូត្រច្រើនពណ៌ក្រហម - លឿង - ខ្មៅ - ខៀវ ទុកឲ្យសខ្វះពេលដែលអនួង ដួនកាលមេអមសខ្មៅ ដួនកាលផាក់មេអមខ្មៅ - ខៀវ ផ្លាស់

ក្រឡាតាមចិត្ត អ្នកជម្នាញស្រឡាញ់ ប្តូរនិយមតាមអ្នកស្រុកគេប្រើ សព្វថ្ងៃគេសន្មតឲ្យឈ្មោះតែពីរ គឺសារុងពណ៌ ១ សារុងស ១ ៗ ក្អិនស្ងួត ១ ម៉ឺ ធ្វើបានសារុង ៩ ទាំងបាក់ទាំងអន្ទង បណ្តោយ ១ ម៉ែត្រ ៨ តឹក ទទឹងឈើ ១ ម៉ែត្រ ១ តឹក ៗ

៤ – អធិប្បាយអំពីព្រលាត – គឺគេធ្វើសស្ងួត ដូនកាលមានផ្កាខ្វះតែសដដែល ទើបគេយកមកដាំនមាក់គ្រឿងឲ្យខ្មៅ ធ្វើជាសំពត់ស្រីៗ ក្អិនស្ងួត ១ ម៉ឺ ធ្វើបាន ២៥ ម. ទាំងបាក់ទាំងអន្ទង ៗ

របៀបធ្វើស្ងួតអស់តែប៉ុណ្ណេះ ខ្ញុំបាទធ្លាប់ធ្វើផ្ទាល់ខ្លួន រេះតាំងពីឪពុកខ្ញុំមកដរាបមកដល់សព្វថ្ងៃនេះ ខ្ញុំធ្វើរបរនេះជាមួយនឹងម្តាយខ្ញុំ សព្វតែត្បាញក៏ខ្ញុំចេះដែរ ៗ

កាលបើក្រុមជំនុំទំនៀមទម្លាប់ មានសេចក្តីសង្ស័យ សូមទៅសួរខ្ញុំបាទចុះ ខ្ញុំបាទនឹងជំរាបតាមចេះចាំដោយសព្វគ្រប់ ៗ

**ចប់របៀបធ្វើស្ងួតតែប៉ុណ្ណេះ**

លោកកយ - ប៉ុក ក្រមការ រៀបរៀង

(តមក)

---

## បណ្ឌិតវគ្គ (ត)

៣១ – ការជំនួញជាប្រទីបពួកពាណិជ ក្រុមសង្ឃក៏ប្រមានប្រទីបគឺធម្មា កលសង្គ្រាមជាប្រទីបពួកយោធា ច្បាប់មាត្រាជាប្រទីបចៅក្រម ។

៣២ – លោកធ្វើមាត់មួយម្រាមដៃដប់ សង្ខារប្រាប់ពួកសត្វប្រដៅ ត្រូវដៃធ្វើការជាងចៅហ្វៅ មិនត្រូវនៅស្ងៀមកើតជាមនុស្ស ។

៣៣ – ការហាត់ច្បាប់ប្រាណ ស្វាធ្យាយលំអាន គិតគូរច្បាប់បិត្ត កែប្រែចម្រើន ច្បាប់ជាតិក្រមក្រិត្យ រួមមូលមួយមិត្រ ពិតច្បាប់សាសនា ។

៣៤ – សុនខព្រៃពូកែបស្សាវៈ បដ្ឋមនខៈ ពូកែខាងខ្លា មាន់ជល់ពូកែផ្ទាល់សោតណា គំនិតប្រាជ្ញាពូកែខាងមនុស្ស ។

៣៥ – ផរវែងប្រែទ្វី ធម្មជាតិលោកិយ ប្រែតាមសង្ខារ ស៊ីវិល័យប្រទេស អាទិត្យចន្ទ្រា ចាស់ប្រែកុមារ រាជធម្មាពិត ។

៣៦ – បុប្ផាកុលាប តែងមានបែបភាព បន្ទាស្រួចមុត សត្វមនុស្សក្តីមិត្ត មិនបានសុខសុទ្ធ ចៀសទុក្ខមិនផុត កុំឲ្យប្រមាទ ។

៣៧– បណ្ឌិតព្រឹទ្ធាចារ្យ បុរាណបឋមកាល ប៉ាត់ឈ្មោះបក្រាឡ ឬមាននាមលុះសព្វថ្ងៃ លោកដាំស្រែវិទ្យា មានគុណថ្លៃប្រសើរពិត ។ ប្រាសាទមានគូបធំ អភិរម្យតាមគំនិត បុរាណយល់និមិត្ត មានឆ្ងាយជិត ទុកស្នាដៃ រូបកាយជាអនិច្ចា ប៉ាត់អាត្មាសូន្យគ្រប់ថ្ងៃ តែនាមគោត្រ បច្ច័យ ទុកនិស្ស័យឲ្យបាក្រោយ ។

៣៨ – មនុស្សចាស់ក្មេងកុំប្រមាទ ក្មេងខំសង្វាត ចាស់កុំមើលងាយ ។ ក្មេងគោរពចាស់លោកទាយ ថាអាចពណ្ណរាយ ក្នុងនាលោកិយ ។ ក្មេងខំរៀនសូត្រឃ្មាតខ្មី ចាស់ទុំពោលស្តី ថាពស្នាទាប ៗ តាមពិតត្រូវគិតតាមភាព បុណ្យក្មេងខ្ពស់ទាប សឹងស្មានពុំត្រូវ ។

៣៩– ខ្សែរឹតខ្លាំងដាច់ ពត់រុក្ខាស្រេច ខ្លាំងបាក់ខ្ចាត់ខ្ចាយ ត្រង់ការពត់មនុស្ស ខ្លាំងទុក្ខអន្តរាយ ពត់ចិត្តមិនងាយ ក្មេងស្រួលពត់ចាស់ ។

៤០ – មានហេតុមានផល សង្គ្រាមសាកល កើតឧបាទាន អគ្គីឆាបឆេះសម្រាម់ប្រធាន ក៏យោបក់ប្រាន ស៊ុកឈើរីក បាបបុណ្យ គុណទោស កសាងតាមថ្នាក់ រូបល្អសមស័ក្តិ ផ្ចិតកាន់សីលា ។

៤១ – ខ្ពស់ណាស់ឃើញដី ទាបណាស់មេឃស្តី ច្រើនណាស់ព្រួយទុក តិចណាស់ព្រួយរក តូចណាស់ឃើញមុខ ហត្ថីសត្តុក ធំឃើញស្រមោច ។

៤២ – ក្នុងដីឃើញប្រាក់ កពឃើញកងចក្រ ក្នុងជាតិតស្រេក
ក្នុងរូបឃើញចិត្ត ឃើញពេជ្រសិលា ខន្ធវិបស្សនា ចិត្តានិព្វាន ។

៤៣ – មានប្រាក់បេះបាយ បេះធីមានបាយ មានមនុស្សបេះប្រើ
មានជាតិបេះសួន មានស្លាបបេះហើរ បំណោះបេះស្មើរ តែងជិះកងឯង ។

៤៤ – ពូជហង្សាមិនបោលស្រះឈូក មិនបោលប្រមាទជ្រូកសូករៈ
ពូជទារមិនបោលការបោកផាក់ ពូជលាមកមិនបោលទុច្ចរិត ។

៤៥ – ពូជសត្វកសាង ព្រៃព្រាណដុសលាង ដូចកាប់ផ្ទៃដូង
ត្រូវបកសំបក ខាតប្រើនពេលម៉ោង លោតុសរូង ទើបបានបរិភោគ ។
ស្អាងជាតិព្រៃគ្រប់ កំរិតប្រាជ្ញ រំលំរបៀបយបោក កាប់ដូងមិនដាច់
គោកផ្ទុកសោយសោក សូមរលកង់លោក ដំយដោតប្រាជ្ញា ។

៤៦ – ស្រឡាញ់កុំសូមទ្រព្យប្រសើរ ពីក្មេកមាក់នាំខូចចិត្ត
បៀបយកព្រះខាន់តម្រង់ពិត ត្រង់កគួរគិតក្បែយដីវ ។

៤៧ – ប្រាក់ចាយគង់អស់ ពោលពាក្យសប្បុរស ចាយក្រពន់ពេក
បើចាយខាងល្បែង ក្រមានអនេក វិទ្យាបេះថ្វែក ចាយបែកនៅពេញ ។

៤៨ – បើចង់ចុះមៀន ឲ្យបកប្រឹតប្រៀន សំបកបោលសិន
ទើបចុះសាប់ស រសៀផ្អែមឈ្ងុយក្លិន កុំធ្វើស្រពន់ ធីទាំងសំបក ។
រហ័សណាស់ខាត យឺតយូរគង់ខូច គិតរួបសឹមរក ផ្លូវល្អអាក្រក់
គួរដឹងភាពប្រែក លំបាកវែកបក ត្រូវស្គាល់សព្វគ្រប់ ។

៤៩ - ពេលិតខៅក្រហមគ្រោតគ្រាតគ្រៅ បកសំបកទៅប្រផាស ផ្លែគ្មាតស្រអាប់សាច់ក្នុងល្អ មានទឹកក្នុងកជាតិផ្អែមរស ។ តសំបក គគ្រើមមិនស្អាត ក្នុងមានជាតិសសាច់សោតសោះ រូបអាក្រក់កុំមើល ងាយមនុស្ស មានប្រាជ្ញាយសគ្គមក្រែ ។

៥០ - អ្នកណាអួតខ្លួនថាប្រាជ្ញពោក តាមភាពប្រយោគលង់លើ-សលុប អ្នកណានៅស្ងៀមក្តីថ្ងៃយប់ អ្នកផង់គោរពចូលសាកសួរ ។

៥១- មនុស្សសត្វបក្សី នៅនាក្រុងក្រែ ឆ្លាតជាងស្រុកស្រែ ព្រោះ មានសុរិល័យ តែងប្រាជ្ញគេចកែ បញ្ចប្រលប្រែ មានប្រាជ្ញាច្រើន ។

៥២ - អ្នកណារៀនបេះក្បួនច្បាប់ច្រើន តែមិនក្រើនកិច្ចអាត្មា ប្រមាទមើលងាយការធម្មតា គិតថាខាបចោកច្រើនអត់ប្រាយ ។ គេស្គាល់ប្រាជ្ញដោយការធម្មតា ប្រសើរអស្ចារ្យព្យាយាមកាយ គិតគួរ ធ្វើចំរើនផ្សព្វផ្សាយ វត្តស្រុកអាយមានគេក្តីឈ្មោះ ។ ធម្មជាតិរបស់ងាយ ធ្វើមិនបាន ទៅចង់បួរប្រាណប៉ងចាក់ផ្តុះ គ្រៀងចក្រយន្តវិលកប៉ាល់ ហោះ ដូចបុរសខ្វិនអួតចង់រត់ៗ បើខ្សៀងវក្តាខ្សៀងពីគល់ ខ្សៀងផ្តុះមណ្ឌល ដណ្តើរបត់ ត្រូវរៀនមោកខំកត់ ទើបបានកំណត់មើល សៀវភៅ ៗ

# ស័ព្ទបារាំងប្រែជាខ្មែរ

របស់

*គណកម្មការវប្បធម៌*

# ហ្លួងទិពទ្ធមន្ត្រី ញុក-ថែមប្រមូល

(តមក)

---

Crise ministérielle = វិបត្តិរដ្ឋមន្ត្រី-

Antipathi = វិសមានចិត្ត
(21 -2 48)

Inspecteur de l'Enseignement Primaire = អធិការបឋមសិក្សា

Inspecteur en chef de l'Enseignement Primaire = អធិការ-
នាយកបឋមសិក្សា

Inspecteur adjoint de l'Enseignement Primaire = អធិការ-
នាយករងបឋមសិក្សា

Inspecteur d'Education Physique = អធិការកាយសិក្សា

Directeur d'Ecole Primaire Complémentaire = ចាងហ្វាងសាសា
បឋមសិក្សា បំពេញវិជ្ជា

Mo iteur des Ecoles rurales = គ្រូបង្ហាត់សាលាជនបទ

Directeur d'Ecole Primaire Elémentaire = ចាងហ្វាងសាលា-
បឋមសិក្សាថ្នាក់ដំបូង-

Moniteur des Ecoles de pagodes = គ្រូបង្ហាត់សាលាវត្ត

Moniteur de l'Enseignement technique (École professionelle)

គ្រូបង្ហាត់សាលាទេកនិក ( សាលាវិជ្ជាជីវសិក្សា )

Moniteur D'Education Physique = គ្រូបង្ហាត់កាយសិក្សា

Instituteur auxiliaire journalier = គ្រូបង្រៀនជំនួយទិនិក

Instituteur = គ្រូបង្រៀន

Education = ការហ្វឹកហ្វឺន, ការប្រៀនប្រដៅ;

ការអប់រំ

Instruction = ការសិក្សា

Enseignement = ការបង្ហាត់, បង្រៀន

Moniteur = គ្រូបង្ហាត់

Instituteur = គ្រូបង្រៀន

professeur = អាចារ្យ, សាស្ត្រាចារ្យ

Maître = គ្រូ

journalier = ទិនកជន

(27– 2 48)

Certificat = វិញ្ញាបនប័ត្រ

Aptitude = សម្បទា

Brevet = ប្រកាសនីយប័ត្រ

Diplôme = សញ្ញាប័ត្រ

Certificat d'Aptitude Pédagogique franco khmer = វិញ្ញាបនប័ត្រ គរុកោសលសម្បទា

Pour les instituteurs auxiliaires = សម្រាប់គ្រូបង្រៀនជំនួយ

Brevet d'Aptitude Pédagogique (Pour les instituteurs) = ប្រកាសនីយប័ត្រគរុកោសល (សម្រាប់គ្រូបង្រៀន)

Certificat de fin d'Etudes normales Cambodgiennes = វិញ្ញាបនប័ត្រចប់ការរៀនគរុវិជ្ជាខ្មែរ—

Certificat d'Aptitude à l'Enseignement Elémentaire Camdodgien (Pour les bonzes instituteurs) = វិញ្ញាបនប័ត្រសម្បទាសម្រាប់ការសិក្សាជាន់ដំបូងខ្មែរ (សម្រាប់គ្រូបង្រៀនលោកសង្ឃ) ។
(1:-3 48)

Certificat d'Aptitudes aux fonctions de Directeur d'Ecoles d'Application ou d'Inspecteur des Ecoles de pagodes rénovées= វិញ្ញាបនប័ត្រសម្បទាខាងមុខការចាងហ្វាង-សាលាអនុវត្តន៍ឬអធិការសាលាវត្តទំនើបថ្មី ។

Cours Enfantin = កុមារដ្ឋាន

Cours Préparatoire = បរិច្ឆនដ្ឋាន

Cours Elémentaire = អាទិកដ្ឋាន

Cycle primaire Elémentaire = បឋមភូមិជាន់ដំបូង ៗ

Cours Moyen 1er Année = មធ្យមដ្ឋានឆ្នាំទី ១

— 2e — = — ឆ្នាំទី ២

Cours Supérieur = ឧត្តមដ្ឋាន

Cycle primaire complémentaire = បឋមភូមិបំពេញវិជ្ជា—

Equité = សមភាព

Iniquité = វិសមភាព

Homogène = ឯកត្តភាគ, សភាគ

Hétérogène = នានត្តភាគ, វិសភាគ

Impartial = គតិគមន៍ (មិនលំអៀង)

Partial = អគតិគមន៍ (លំអៀង)

Appliquer = អនុវត្ត

Application = អនុវត្តន៍

Rénové = បែបថ្មី—

(5 -៥—48)

Fonction = មុខការ, ដំណែង, ប្រព្រឹត្តិការ
មុខក្រសួង,

Fonctionnement = ការប្រព្រឹត្តទៅ

Fonctionner = ប្រព្រឹត្តទៅ

La saisine = គាហបញ្ញា (សេចក្ដីបង្គាប់ពី-
លោកចាងហ្វាងឲ្យរកហេតុ )

Prendre en considération = ទទួលពិចារណា

Enfin = ក្នុងទីបំផុតនេះ

Procédure = នីតិក្រម

(Le) procédé = វិធីធ្វើ

Carte de visite = នាមប័ណ្ណ

Carte d'Identité = ប័ណ្ណសំគាល់ខ្លួន ( អត្ត-
សញ្ញាណប័ណ្ណ )

Prestation en nature = ការកាលិកប័ត្រធម្មជាតិ

Carte de Rationnement = បរិភោគប័ណ្ណ

Carte d'alimentation = ភោជនិយប័ណ្ណ

Circulaire = សារាចរ

Comité de solidarité = គណៈកម្មាធិការសាមគ្គីធម៌

(10–3–48)

Vacance = វិស្សមកាល

Récréation = វិស្សមោកាស

Secrétariat du Gouvernement = លេខាធិការដ្ឋាននៃរដ្ឋាភិបាល ។

Paria = ចណ្ឌាល (ឬ. ចណ្ឌាលី)

Repos = ការសម្រាក

Congé = ការឈប់សម្រាក

Loi de l'offre et de la demande = ច្បាប់ធម្មជាតិលក់ទិញ

Colonne du journal = ខ្ទង់សារពត៌មាន

5e Colonne = ជួរទី ៥

Le palais du gouvernement de la ville = សាលាក្រុង

Titre ចំណងជើង, ងារ, ឋានន្តរ

(23-3-48)

Editorial = វិចារណកថា

Cycle primaire supérieur = បឋមភូមិជាន់ខ្ពស់

1er année = ឆ្នាំទី ១

2e – ឆ្នាំទី ២

3e – ឆ្នាំទី ៣

4e – ឆ្នាំទី ៤

Enseignement secondaire moderne National = មធ្យមសិក្សា

បែបថ្មីសម្រាប់ជាតិ

Classe de 6e ថ្នាក់ទី ៦

| | |
|---|---|
| — — 5e | — ៥ |
| — — 4e | — ៤ |
| — — 3e | — ៣ |
| — — 2e | — ២ |
| — — 1er | — ១ |

Mathématiques élémentaires ou Philosophie — គណិតសាស្ត្រ ជាន់ដំបូងឬទស្សនវិជ្ជា

Commission = សគុណ (សម្រាប់ដំនួញ)

(Le 9—4 48)

Loi = ច្បាប់

Décret = ក្រឹត្យ

Décision = សម្រេច (សម្រាប់គណៈរដ្ឋមន្ត្រី)

Arrêté = អនុក្រឹត្យ

Décision = ដីកា (សម្រាប់ចៅហ្វាយខេត្ត)

Ministère de l'agriculture = ក្រសួងកសិកម្ម

Bureau du personel = ប៊ុយរ៉ូបុគ្គលិក

(Le 13 - 4 - 48)

Grade = ឋានន្តរសក្តិ

Classe = ថ្នាក់

Cadre = ក្របខ័ណ្ឌ

Renaissance khmère = ខេមរបដិការ

Décoration (Distincion honorifique = គ្រឿងឥស្សរិយយស–

Médaille de la reconnaissauce de la Nation aux membres de l'Enseignement en or (en argent) មេដាយមាស (ប្រាក់) ជាតិ-បដិការសម្រាប់សមាជិកសិក្សាធិការ

Palme de l'académie en or (en argent) — គាលប័ត្រមាស(ប្រាក់)

Bureau de la comptabilité = ប៊ុយរ៉ូបញ្ជី

Comptable = អ្នកបញ្ជី

Secrétaire particulier = លេខាធិការផ្ទាល់

Secrétariat = លេខាធិការដ្ឋាន

Agriculture = កសិកម្ម

Agriculteur = កសិករ

Elevage = ការចិញ្ចឹមសត្វ

Eleveur = អ្នកចិញ្ចឹមសត្វ

Eaux et Forêts = គង្គា ទឹងព្រៃ

pêche = នេសាទ

Chasse = ប្រមាញ់

Chasseur = ព្រាន

Riziculture = ក្សេត្រកម្ម

(Le 16 - 4 48)

Partisan = បក្សពន្ធ

Règle = ក្បួនខ្នាត

Règlement = បទបញ្ជា

Document = ឯកសារ

Archive = ទីទុកឯកសារ

Archiviste = អ្នកឯកសារ

Documentation = ការបង្ហាញឯកសារ

Etude = ពិនិត្យគ្រោងការ

Propagande = ឃោសនាការ

Domaine public = ដែនសាធារណៈ

Domaine privé = ដែនឯកជន

Bureau d'ordre = ប៊ុយរ៉ូរបៀប

Arrivée = សំបុត្រចូល

Départ = សំបុត្រចេញ

Titre = ឋានន្តរ

Attaché militaire = សេនានុពន្ធ

Directeur des affaires politiques, administratives sociales, et culturelles= នាយកនៃកិច្ចការខាងនយោបាយ ខាងរដ្ឋបាល, ខាងសង្គមនិងខាងវប្បធម៌

Salle de conférence = សាលាសន្និសីទ

Causerie = បាឋកថា

Directeur des affaires économiques et financières = នាយកនៃកិច្ចការខាងសេដ្ឋកិច្ច និងខាងហិរញ្ញវត្ថុ

Directeur des bureaux administratifs = នាយប៊ុយរ៉ូរដ្ឋបាល

Inspection en chef de l'Enseignement primaire = មន្ទីរអធិការនាយកបឋមសិក្សា

Service d'ordre = ក្រុមរបៀប

Réunion, Bibliothèque = សន្និបាត, បណ្ណាល័យ

Etablissement scolaire = គ្រឹះឋានសិក្សា

Bourses = អាហារូបករណ៍

Secours scolaire = ជំនួយសិក្សា

Office des Etudiants Cambodgiers = មន្ទីរសង្គហនិស្សិតខ្មែរ

Propagande, Publication et organisation sociale scolaire = ឃោសនាការ, និងការរៀបចំ, សង្គមសិក្សា

(Vendredi 30 - 4 - 48)

(មាត)

# ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

ឯសាសនាព្រាហ្មណ៍ដែលយើងបានពណ៌នាមកហើយនោះ កាលបើពិគ្រោះមើលទៅ ក៏មិនឃើញអ្វីល្អវិសេសលើសលែងសាសនាដទៃ ៗ នុះទេ ប៉ុន្តែជាសាសនាដែលមិនចេះរលំរលាយផ្តួលមិនដួល ; ព្រះពុទ្ធក្តី ព្រះមហាវីរៈក្តី ព្រះមហាហម្មត់ក្តី ព្រះយេស៊ូក្តី ទុកជាបានផ្ចាញ់ផ្ចាលតស៊ូនឹងសាសនាព្រាហ្មណ៍យ៉ាងណាក៏ដោយ សាសនាព្រាហ្មណ៍នៅតែមានអាការខ្ជាប់ខ្ជួនរឹងប៉ឹងមិនចាញ់ក្ស័យមាល័យឡើយ ហើយស្ថិតស្ថេរផ្សាយទូលាយចេញទៅ រហូតមកដល់ក្រុងកម្ពុជាដែលជាដែនព្រះពុទ្ធសាសនាសុទ្ធ ៗ ក៏នៅតែមានមនុស្សនិយមកាន់តាមជាច្រើនដែរ ។

តាំងអំពីលទ្ធិព្រះពុទ្ធសាសនា បានបែកខ្ញែកគ្នាជា ២ និកាយហើយ ៗ បានផ្សាយចេញទៅរហូតដល់ស្រុកចិនក៏ដោយ ចំណែកខាងឥណ្ឌាមានតែទ្រុឌទ្រោមចុះទៅ សាសនាព្រាហ្មណ៍ត្រឡប់ជាចំរើនរុងរឿងឡើងវិញ ហើយតមកគ្រាក្រោយនេះ ខាងលទ្ធិមហាយានបានចាត់បង្កើតលទ្ធិថ្មីឡើង ១ ទៀតហៅថា លទ្ធិ តន្ត្រិស្ម៍ ។

ឯលទ្ធិតន្ត្រិស្ម៍នេះកើតឡើងដោយគំនិតរបស់ពួកមហាយាន ដែលយល់ថា បើបានបញ្ចូលលទ្ធិអ្វីថ្មីឡើង នឹងធ្វើឲ្យសាសនាបានរុង

រឿង ១ ស្របក់មិនខាន ដូចជាការតាំងបង្កើតលទ្ធិមហាយានឡើង ជាការជួយឲ្យព្រះពុទ្ធសាសនាផ្សាយចូលទៅក្នុងស្រុកចិនបាន តែពួកនេះមិនបានពិចារណាឲ្យជ្រៅជ្រះថា ការណ៍ដែលលទ្ធិមហាយានបានផ្សាយចូលទៅក្នុងស្រុកចិនបាននោះ មិនមែនដោយអំណាចលទ្ធិមហាយានទេ តាមពិតនោះ ផ្សាយចេញទៅបានដោយអានុភាពរបស់ព្រះមហាក្សត្រទេតើ! បើទុកជាគ្មានលទ្ធិមហាយាន ព្រះពុទ្ធសាសនាក៏នៅផ្សាយចូលទៅក្នុងស្រុកចិនបានដែរ ហេតុដូច្នេះការដែលតាំងលទ្ធិត្រិស្ត៍ដោយយល់ថា នឹងធ្វើឲ្យព្រះពុទ្ធសាសនាចំរើនរុងរឿងជាការយល់ខុសទាំងស្រុង ៗ មួយវិញទៀត លទ្ធិត្រិស្ត៍នេះ មិនមានធម៌អាចជាខឹមសាររបស់ព្រះពុទ្ធសាសនាសោះឡើយ មានតែបញ្ញត្តិវេទមន្ត-គាថា ហើយបញ្ញត្តិថា បង្កាត់ភ្លើងឡើងធ្វើពិធីយ៉ាងនោះ ៗ អាចនឹងបានឡើងស្ថានសួគ៌ ឬទៅនិព្វានបានភ្លាម ៗ លទ្ធិនេះប្រហែលគ្នាយកឈ្មោះព្រះពុទ្ធសាសនាទៅស្រោបពីខាងក្រៅសាសនាព្រាហ្មណ៍ ធ្វើឲ្យសាសនាត្រឡប់តាំងខ្លួនឡើងវិញបាន ៗ ការដែលលទ្ធិត្រិស្ត៍-ផ្សាយចេញទៅបាន ដោយអាស្រ័យពួកក្សត្រវង្សរាជពុតជួយទំនុកបំ-រុងផង ហើយវង្សរាជពុតនេះ ជាអ្នកកាន់ខ្ជាប់ខ្ជួនក្នុងលទ្ធិសាសនាព្រាហ្មណ៍ កាលបានចូលទៅគ្រប់គ្រងនៅខេត្រដែនណា ក៏ធ្វើឲ្យខេត្រដែននោះក្លាយទៅជាសាសនាព្រាហ្មណ៍ផង ដូច្នេះហើយទើប

ព្រះពុទ្ធសាសនាវិញចយកតែចេញទៅនៅខាងក្រៅ ៗ គឺខាងកស្មីរៈ, នេប៉ាល, បង្គាល, និងលង្កា ៗ ក្នុងសេចក្ដីកត់ហេតុរបស់ព្រះសមណយួនធាងប៉ានសំដែងឲ្យឃើញថា ក្នុងសម័យដែលលោកចូលទៅប្រទេសឥណ្ឌានោះសូម្បីមានក្សត្រិយ៍ជាច្រើនអង្គ នៅតែខ្ជាប់ខ្ជួនក្នុងព្រះពុទ្ធ-សាសនាក៏ដោយ តែបណ្ដាប្រជាជនត្រឡប់កាន់លទ្ធិសាសនាព្រាហ្មណ៍ជិតអស់ហើយ លុះមកដល់ព្រះពុទ្ធសករាជ ១២៥០ ព្រះវិស្ណុ និងព្រះសិវៈក៏ចំរើនរុងរឿងឡើងយ៉ាងក្រៃលែង ទើបនាំឲ្យលទ្ធិសាសនាហិណ្ឌូផ្សាយរីកពាយចេញទៅទៀតជាច្រើន ៗ

ឯពាក្យថា ហិណ្ឌូ ៗ នេះ ជាឈ្មោះថ្មីរបស់សាសនាព្រាហ្មណ៍ដោយមានរបៀបគោលបារិកនឹងពិធីកែប្រែប្លែកពីលទ្ធិដើម របស់ព្រាហ្មណ៍ខ្លះដែរ យើងបានដឹងពីខាងដើមមកហើយថា សាសនាព្រាហ្មណ៍ជាន់ដើមមានព្រះជាធំខ្ពង់ខ្ពស់បំផុតតែមួយទេ គឺព្រះព្រហ្មតែកាលខាងព្រះពុទ្ធសាសនាមាន ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃជាគោលបារិក ៣ ប្រការ ដែលហៅថា ព្រះរតនត្រៃឡើងហើយ ពាក្យថាត្រៃរតន៍ក្លាយទៅជារបស់សំខាន់ លទ្ធិគ្រិស្ដសាសនាក៏មានបញ្ញត្តិឡើងដែរហៅថា ត្រីនិតេ (Trinité) គឺ ព្រះបិតា, ព្រះបុត្រ និងព្រះវិញ្ញាណ ៗ ឯសាសនាព្រាហ្មណ៍ក៏ចង់ឲ្យធំសំបើមឡើងដែរ ក៏ត្រូវតែមានដូចគេដែរ ទើបដំឡើងដំណែងព្រះវិស្ណុ ដែលជាន់ដើមជាព្រះ

ជាន់បន្ទាប់នោះឲ្យខ្ពស់ឡើងមក ហើយបានព្រះសិវៈមកមួយអង្គទៀតរួមគ្នាទាំង ៣ អង្គឲ្យឈ្មោះថា ត្រីមុរតិ ។ ឯព្រះសិវៈដែលយើងធ្លាប់ហៅថាព្រះឥស្សូរនោះ តាមគម្ពីរវេទនិយាយថាជាអង្គជាមួយគ្នា រូបដែលមិនមែនជាព្រះឥណ្ឌៀប៉ែកខាងអរិយកសុទ្ធសាតទេ គឺពួកព្រាហ្មណ៍ទៅយកមកអំពីពួកមិលក្ខៈហើយយកមកតាំងឲ្យធ្វើធំឡើង ដើម្បីប្រឡោមចិត្តពួកមិលក្ខៈឲ្យចូលកាន់សាសនាព្រាហ្មណ៍ច្រើនឡើង ហើយរួមជាតែរតនរបស់ហិណ្ឌូ ទើបនាំឲ្យលទ្ធិសាសនាហិណ្ឌូផ្សាយចេញបានច្រើន ហើយក្លាយទៅជាម្ចាស់ប្រទេសឥណ្ឌៀជាជំនួសព្រះពុទ្ធសាសនា ដែលធ្លាប់ចំរើនរុងរឿងមកពីដើម ហើយធ្លាប់ធ្វើបុណ្យ គុណទុកដល់ប្រទេសឥណ្ឌៀជាអនេកប្រការ ។ សាសនាព្រាហ្មណ៍កាលបានឈ្មោះថាហិណ្ឌូហើយ ក៏កើតមានលទ្ធិបំបែកឡើងទៀតជាច្រើន ដូចជាបូជាសិវៈលិង្គជាដើម ។ មានសៀវភៅរបស់រ៉េនេរគ្រុសេតពោលទុកថា” ឥណ្ឌៀដែលជាប្រទេសរបស់អ្នកប្រាជ្ញ ចំរើនរុងរឿងដោយសិល្បវិជ្ជា ជាដែនដីនៃព្រះសាក្យមុនី ជាមហាអាណាចក្ររបស់ព្រះបាទអសោក និងព្រះបាទមិលិន្ទ កាលអស់បុណ្យមហាបុរសទាំង ៣ ហើយ បណ្ដារាស្ត្រនាំគ្នាមកប្រជុំក្រាបថ្វាយបង្គំលិង្គនិងយោនីទាំងហ្វូង ។

**ចប់វគ្គទី ៤ តែប៉ុណ្ណោះ**

### វគ្គទី ៥

# ឥណ្ឌៀភាគខាងត្បូង

តាំងអំពីវគ្គទី ១ ដល់មកវគ្គទី ៤ នេះ យើងនិយាយអំពីរឿងរ៉ាវរបស់ឥណ្ឌៀភាគខាងជើង ដែលជាដែនដីរបស់ពួកអារិយកៈដោយច្រើន ៗ ឯរឿងរ៉ាវរបស់ឥណ្ឌៀ នៅមានសេចក្ដីសំខាន់ ១ ភាគទៀតគឺឥណ្ឌៀភាគខាងត្បូង ពីដើមហៅថា ពួកមិលក្ខៈ តែតមកសម័យក្រោយ ពួកនេះមានសេចក្ដីចំរើនរុងរឿងឡើងច្រើនមិនចាញ់ពួកខាងជើងទេ ដូចមានរឿងរ៉ាវគួរពោលទុកដោយសង្ខេបដូច្នេះ

ឥណ្ឌៀភាគខាងត្បូងដែលហៅថាដិកកន ជាដែនដីរបស់ពួកមិលក្ខៈ នោះមានផ្ទៃដែនដីដោយច្រើនជាភ្នំមានក្រួសរពន ហើយដេរដាសទៅដោយភ្នំតូច-ធំ ពួកមិលក្ខៈដែលបានពោលមកហើយ ជាម្ចាស់ដែនដីឥណ្ឌៀនៅភាគខាងជើងអំពីដើម ហើយត្រូវពួកអារិយកៈលុកលុយដូចមានសេចក្ដីក្នុងវគ្គទី ១ ហើយ ទើបនាំគ្នាថយចុះមកទិសខាងត្បូង ហើយបានចាត់តាំងអាណាចក្រផ្សេង ៗ អាណាចក្រខ្លះនៅតែឯងមិនទាក់ទងនឹងពួកអារិយកៈ មានអាណាចក្រខ្លះចងស្ពានមេត្រីនឹងពួកអារិយកៈ ហេតុដូច្នេះហើយ បានជាមានអាណាចក្រខ្លះដូចមហារាស្ត្រ បានទទួលយកអារ្យៈធម៌មកអំពីពួកអារិយកៈរក្សាទុកដោយល្អ មានអាណាចក្រខ្លះគឺ តេលុគុ, ទមិឡ; និងមីសូរ មានអារ្យធម៌របស់ខ្លួនឯងសុទ្ធ ៗ មិនច្របូកច្របល់នឹងពួកអារិយកៈសោះឡើយក៏មាន ៗ

អាណាចក្រផ្សេងៗ ខាងដិកកិននេះ មានឈ្មោះហៅម្យ៉ាងទៀតថា ឥណ្ឌៀខាងមាត់សមុទ្រ ។ ភូមិប្រទេសចែកចេញជា ៤ អន្លើគឺៈ ម៉ាលវៈ ១ គនដ៍វនៈ ១ ដិកកិន ១ មីសូរ ១ ។

ខេត្តដែនម៉ាលវៈជាទីទួលខ្ពស់ តាំងនៅក្នុងរវាងទន្លេយមុនានិងភ្នំវិន្ធយៈនិងភ្នំអារាវលី ជាទីមានផ្ទៃដីខ្ពស់ៗ ទាបៗ ចែកចេញជា ៣ អន្លើ គឺឧជ្ជេន, ក្វាលីអរនិងគណ្ឌូ ។ ឯដែនដីគនដ៍វនៈនោះ តាំងនៅខាងជើងស្ទឹងនារ៍បាដា និងស្ទឹងសោន;ជាទីស្តុកទៅដោយព្រៃព្រឹក្សា ហើយនៅទិសខាងកើតនៃដែនដីចំណែកនេះ ជាលំនៅរបស់ពួកគនដ៍ ដែលជាមនុស្សព្រៃ ១ ពួករបស់ឥណ្ឌៀមានសំបុរខ្មៅដូចពួកណេគ្រ៍ រហូតមកដល់សម័យនេះ ពួកនេះនៅតែសាត់ត្រាត់មិនមានលំនៅជាឡាក់បានឡើយ ។

ចំណែកឯដែនដីដែលហៅថា ដិកកិន សុទ្ធៗ នោះជាទីពាសពេញទៅដោយភ្នំតូចៗ និងជាទីទួលខ្ពស់នៅមាត់ ទន្លេគោធាវ៉ារីនិងក្រិស្ណា នៅទិសខាងលិចមានទួលខ្ពស់ៗ រហូតទៅដល់សមុទ្រអូម៉ាន។ ក្នុងខេត្តដែនដិកកិននេះជាទីមានសត្វសាហាវនៅពាសពេញ មានស្រុកផ្សេងៗ ដូចនាសិក, ប៉ូណាៈ និងសាត្រាៈ ក្នុងតំបន់អស់នេះជាដែនដីរបស់ពួកមហារាស្ត្រ ដែលពួកជននៅក្នុងមានកំឡាំងមាំមួនល្អ ហើយជាទាហានដ៏អង់អាច ប៉ានធ្វើការលុកលុយចូលមក ហើយចាត់តាំងវង្ស

ក្សត្រគ្រប់គ្រងទីផ្សេង ៗ ត្រាតែទៅជាពួកដែលមានរិទ្ធិអំណាចដ៏ធំសំបើមនៅដែនដីឥណ្ឌៀភាគខាងត្បូងនេះ ៗ

ពួកមហាក្សត្រនោះ ដាន់ដើមជាពូជពង្សពួកមិលក្ខសុទ្ធ តែអំណើះកាលតមក ដទពួកនេះបានទទួលអារ្យៈធម៌អំពីពួកអរិយកៈយកមកប្រើ សូម្បីភាសាដែលប្រើសុទ្ធតែមានមូលមកពីសំស្ក្រឹត កាលបើនិយាយអំពីអក្សរសាស្ត្រ ពួកមហាក្សត្របាននាំយកមកអំពីអាណាចក្រផ្សេង ៗ ខាងទំនាបដងទន្លេគង្គាទាំងអស់ ៗ ខ្សែស្រឡាយពួកមហាក្សត្រនេះ មិនបាននៅបំពោះត្រង់ប៉ុណ្ណៈនឹងបុមវៃយ ដែលជាកន្លែងរបស់មហាក្សត្រសុទ្ធ ៗ ប៉ុណ្ណោះទេ នៅមានហៀរចូលទៅក្នុងទំនួលខ្ពស់នៃម៉ាលវៈ នឹងទំនួលខ្ពស់នៃគនដ់វនៈ នឹងខាងទិសខាងកើតនៃទំនួលខ្ពស់របស់ដែនដិកក័នទៀតផង ៗ

ទំនួលខ្ពស់នៅទិសខាងកើតដិកក័ននោះ ជាដែនដីរបស់ពួកតេលុគុ ដែលមានខ្សែស្រឡាយទឹងៈប្រើភាសាមិលក្ខៈសុទ្ធ ពួកនេះបានតាំងទីលំនៅគ្រប់គ្រងដែនដីវាំងទន្លេគោធាវរីនឹងទន្លេក្រិស្ណា ៗ

ឯភូមិប្រទេសរបស់ពួកម័ស្សូរនោះ ជាទីខ្ពស់ ៗ ទាប ៗ ច្រើនបំផុត ទើបនាំឲ្យពួកម័ស្សូរអាចការពារ ទប់ទល់ការលុកលុយបានជានិច្ច ហើយពួកម័ស្សូរសោតទៀតក៏ជាពួកអ្នកចម្បាំងដែលខ្លាំងពូកែ ក្នុងគ្រាដែលអង់គ្លេសចូលមកវាយយកឥណ្ឌៀនោះ អង់គ្លេសតោងខូចពេល

វេលាជាយូរ នឹងប្រើកម្លាំងជាច្រើនទម្រាំតែវាយយកខែត្រនេះបាន ៗ បណ្តាអ្នកស្រុកម៉ស្សូរនោះហៅឈ្មោះថាម៉ស្សូរយាងប្អការនេះ ជាពូជពួកតេលុគុនឹងពួកទមិឡផ្សំលាយគ្នា ៗ

តាំងអំពីទួលខ្ពស់ជាដែនដីរបស់ពួកម៉ស្សូរនេះទៅ មានស្ទឹងមួយហៅថា កាវេរី ដែលមានឈ្មោះម្យ៉ាងទៀតថា "ទន្លេគង្គាខាងក្រោម" នៅតំបន់នេះមានស្ទឹងព្រែកជាច្រើននាំឲ្យផ្ទៃដែនដីមានដីជាតិល្អ មានទីទំនាប ១ អន្លើហៅថាការទុត ជាតំបន់ដែលពួកទមិឡនៅ ៗ ឯពួកទមិឡនេះជាពួកដែលមានសេចក្តីចំរើនរុងរឿងបំផុតក្នុងចំណោមមិលក្ខៈ ជាពួកដែលស្ទាត់ជំនាញខាងការដាំដំណាំ ជាជាងដែលមានថ្វីដៃពូកែផង ៗ ភាសារបស់ពួកទមិឡជាភាសាថ្ងៃថ្លាមានពាក្យនិយមច្រើនច្រើន រហូតដល់សាសនាដទៃក៏បានប្រើភាសានេះ សម្រាប់ចារិកគម្ពីរដីកាក្នុងសាសនាផង ៗ ពួកទមិឡមានកវីដែលបានទទួលសេចក្តីសរសើរថា ជាកវីពូកែបំផុតរបស់គេម្នាក់ ឈ្មោះតិរុវល្លុវ៉ារ ៗ

តាំងអំពីដើមមក អាណាចក្រទាំងឡាយដែលពោលមកហើយនេះ នៅក្នុងឋានៈ ដែលមានសេចក្តីចំរើនតិចជាង ឬនៅជាព្រៃផ្សៃនៅឡើយ ចាញ់អាណាចក្រខាងដងទន្លេគង្គាឆ្ងាយណាស់ គឺមករហូតដល់រាងពុទ្ធសករាជ ១២០០ ឆ្នាំទើបបណ្តាអាណាចក្រនៅចំណែកនេះ ចាប់ផ្តើមប្រឹងប្រែងខំឃ្មាតខ្មីខ្លួនឲ្យបានចំរើនឡើងស្មើនឹងពួកខាងជើង ៗ ការ

ដែលពួកមិលក្ខៈមានសេចក្ដីចំរើនឡើងស្មើនឹងពួកជនទន្ទេតគ្នា ឬថាពួកមិលក្ខៈមានសេចក្ដីចំរើនស្មើនឹងពួកអរិយកៈនោះ ព្រោះអាស្រ័យអាណាចក្រមហាក្សត្រជាសំខាន់ ។

អាណាចក្រមហាក្សត្រនេះ តាំងនៅក្នុងខែត្របុមៃបៃយសព្វថ្ងៃនេះ រាជវង្សក្សត្រដំបូងដែលបានគ្រប់គ្រងអាណាចក្រនេះហៅថា វង្ស គាលុក្យៈ តាំងទីក្រុងនៅស្រុកក៉ាតាប៉ុ ក្សត្រវង្សនេះតាំងឡើងកាលពីពុទ្ធសករាជ ១១០០ ដោយក្សត្ររាជពុត ១ អង្គព្រះនាម ព្រះបាទបុលិកេសីមទី ១ ក្សត្រអង្គនេះបានរួបរួមខែត្រដែនចេ្យង ។ ពង្រីកអំណាចរបស់មហាក្សត្រឲ្យបានធំចំរើនឡើង លុះមកដល់ពុទ្ធសករាជ ១១៥៣ ព្រះចៅផែនដីគ្រងរាជ្យជាដំណតមក ទ្រង់ព្រះនាមថា បុលិកេសុិមទី ២ ពង្រីកអាណាខែត្រឲ្យរីកធំតទៅទៀតរហូតអស់ដែនដិកក័ន ។ ឯគូប្រណាំងប្រជែងយ៉ាងសំខាន់របស់មហាក្សត្រគឺពួកបាលវៈ ជាប្រជាជន ១ ពួកដែលមិនទាន់មានអ្នកចេះពង្សាវតារជាតិនេះពិតប្រាកដទេ គ្រាន់តែយល់ថា ជាពួកប៉ារ៉ធី ដែលបានលើកគ្នាចេញមកត ៗ គ្នា ហើយនៅទីបំផុតបានតាំងឡាក់ដ្ឋានខ្ជាប់ខ្ជួននៅស្រុកការ៉ទ័ត ។ ព្រះបាទបុលិកេសុិមទី ២ ទ្រង់មានជ័យជំនះពួកបាលវៈដណ្ដើមយកខែត្រវង្គិ ជិតមាសុលិបៈត័ម ទើបតាំងរាជវង្សតូច ១ វង្សឡើងថ្មីទៀត ជាសាខារបស់វង្ស គាលុក្យៈឲ្យឈ្មោះថា " គាលុក្យៈខាងកើត " កាលពុទ្ធសករាជ ១១៦៣ ។

ព្រះបាទបុលិកេសុិនទី ២ នេះ ធ្លាប់ធ្វើចម្បាំងទប់ទល់ព្រះបាទសីលាទិត្យ កាលជិតផុតរជ្ជសម័យរបស់ព្រះអង្គនោះ ពួកបាលវៈខាងស្រុកការន័តខាំ គ្នាបះបោរឡើងបំផ្លាញកងទ័ពរបស់ព្រះអង្គអស់ទៅជាច្រើន តែអ្នកទទួល គ្រងរាជសម្បត្តិតមកទ្រង់ព្រះនាម ព្រះបាទវិក្រមាទិត្យៈទី ១ បានប្រាប ប្រាមពួកបាលវៈបានឡើងវិញទៀត ៗ ពុទ្ធសករាជ ១២៨៥ រាជវង្ស ចាលុក្យៈ ដែលគ្រងក្រុងវាតាប៉ិក៏អស់អំណាចទៅ ហើយមានក្សត្រ ១ អង្គទៀតព្រះនាម វង្សរាស្ត្រកូត បានគ្រប់គ្រងខេត្រមហារាស្ត្រហូតដល់ ព្រះពុទ្ធសករាជ ១៩១៦ ព្រះចៅផែនដីអង្គទី ២ នៃរាជវង្សនេះព្រះនាម ព្រះបាទក្រិស្ណរាជទី ១ បានកសាងវិហារកៃលាសឡើងនៅស្រុកអិល្លូរ៉ា ជិតបុមបៃយ៍ រវាងពុទ្ធសករាជ ១៣០៣ ដែលជាវត្ថុសំខាន់ ១ នៃសិល្ប កម្មរបស់ឥណ្ឌា ៗ វង្សរាជកូតនេះឯងដែលបានបំផ្លាញអំណាចពួកបា-លវៈទៅ ហើយជាតិបាលវៈក៏សាបសូន្យអស់ទៅ ដោយអំណាចរបស់ វង្សរាស្ត្រកូតនេះ ៗ តែលុះពួកបាលវៈសាបសូន្យអស់ទៅហើយទើប ពួកទមិឡនៅតំបន់គោលៈ ក៏ប្រែត្រឡប់ជាខ្លាំងពូកែជាជំនួសពួកបាលវៈ ឡើងវិញ ហើយចូលគ្រប់គ្រងខេត្រដែនការន័ត ហើយជាសត្រូវធំ នឹងមហារាស្ត្រទៅទៀត ៗ

លុះតមកដល់ពុទ្ធសករាជ ១៥១៦ ពួកក្សត្រវង្សចាលុក្យៈបានតាំង ខ្លួនឡើងគ្រប់គ្រងខេត្រមហារាស្ត្របានទៀត ហើយហៅវង្សក្សត្រដែល

តាំងឡើងចំនេះថា គាលុក្យៈនៃកល្យាណី ព្រោះបានតាំងទីក្រុងនៅស្រុក កល្យាណី ជិតបុមបៃយ៍នៅក្នុងវេលានេះ ហើយមានអំណាចរហូតដល់ ពុទ្ធសករាជ ១៦៧៣ វង្សគាលុក្យៈក៏បានធ្វើសង្គ្រាមនឹងពួកទមិឡៈតមក ម្តងចាញ់ម្តងឈ្នះ គឺពេលពុទ្ធសករាជ ១៥៤០ ពួកទមិឡៈមានជ័យជំនះ តែតមក ៥០ ឆ្នាំក្រោយទៀត រវាងពុទ្ធសករាជ ១៦០២ ពួកគាលុក្យៈ ត្រឡប់មានអំណាចខ្លាំងឡើងទៀត ហើយបានកំចាត់ពួកទមិឡនៅ ខាងគោលៈបានសម្រេច តែតមករវាងពុទ្ធសករាជ ១៦៥០ វង្សគាលុក្យៈ នៃកល្យាណីក៏វៀវពេយទៅ ទើបតពីនោះមកទៀត ដែនដីនេះក៏ធ្លាក់ ទៅនៅក្រោមអំណាចពួកយាទវៈ ដែលពីដើមជា សកបំណុះពួកគាលុ- ក្យៈ ។ ក្សត្រវង្សយាទវៈនេះ គួររាប់ជាក្សត្រវង្សទី ៤ ដែលនៅគ្រប់ គ្រងដែនមហារាស្ត្រ តាំងអំពីនោះមក អំណាចរបស់ដែនមហារាស្ត្រក៏ ទ្រុឌទ្រាមថយខ្សោយរៀង ៗ ទៅ ហើយកម្លាំងពលក៏ថយខ្សោយចុះ ទៅដោយការសង្គ្រាមនឹងពួកម៉ូស្លីមមិនឈប់ឈរ តមកក្នុងពុទ្ធសករាជ ១៨៦១ ក៏ធ្លាក់ទៅនៅក្រោមអំណាចពួកអ៊ិស្លាម ។

តទៅនេះ យើងនឹងសរសេរនិយាយអំពីពួកទមិឡឡើងវិញ ។

នៅខាងដីរាបភាគខាងត្បូងនៃការទិតនោះ បានអាស្រ័យទន្លេ គាវេរីធ្វើឲ្យទីដីមានជីជាតិល្អ ជាដែនដីដែលពួកទមិឡចូលមកតាំងនៅ តាំងអំពីពេលពុទ្ធសករាជ ៥០០ មកហើយ ។

# រឿងភោគកុលកុមារ

អ្នកឧកញ៉ាព្រះឃ្លាំង ទង រៀបរៀង

(តមក)

---

ខ្ញុំសូមក្រាបលាទៅ ផ្ញើពាក្យនៅក្សត្រថ្លៃថ្លា ពុំបើទ្រង់មេត្តា
អត់ទោសប្រោសសត្វជាខ្ញុំ ៗ ស្តេចស្តាប់ព្រះសុណិសា ក្រាបទូល
លាប្រាប់ដោយដំ-ណើរនោះទើបបរម ក្សត្រាត្រាស់បន្ទូលថា ៗ ហៃបា
បុត្របណ្ឌុល បាមកទូលសុំក្រាបលា អាពុកគត់បើថា បើកតាមព្រម
ចិត្តបំណង ៗ ចូរបាយកមន្ត្រី សេនាពីអាយទៅផង កំដរបុត្រស្ងួនគ្រង
គ្រាន់ប្រយ័ត្នប្រយោជន៍ប្រាណ ៗ ព្រះពោធិវង្កូល ស្តាប់ហើយ
ទូលទៅវិញថា បពិត្រខ្ញុំសូមទាន សូមតែនាងនាថជាយា ៗ នូវ
សេះអាជានេយ្យ ព្រះខ័នជ័យធ្នូសរថ្វា យកទៅផងអាត្មា ក្រែងក្រ
កក្រគ្រាន់ប្រស្រ័យ ៗ ស្តេចស្តាប់រាជបុត្រទូល ក្សត្រតសូរព្រមព្រះទ័យ
បើកបុត្រពីរប្វាថ្ងៃ ពុំឃាំងឃាត់តាមចិន្តា ៗ ទើបព្រះវរជននី ឧប
បុត្រីសោយសោកា បន្ទូលផ្តែផ្តាំថា ហៃកូនស្ងួនសំឡាញ់ម្តាយ ៗ
នាងទៅនឹងស្វាមី ឃ្វាឃ្វាតទូរទីឋានឆ្ងាញ ទៅនៅនគរនាយ ចូរ
ផ្ចិតផ្ចង់ផ្គង់ស្វាគត៍ ៗ ប្រុងប្រាណក្រាបប្រណិបត្ត ព្រះរៀមរត្ន
ជាស្វាមី តាមដោយក្រឹត្យក្រមស្រី កុំឲ្យព្រួយព្រះចិន្តា ៗ ហើយ
កូនកុំបោះបង់ ម្តាយលន់លង់យូរឃ្វាតឃ្វា ម្តាយមានតែនាងជា ថ្មើម

បណ្ដោចបណ្ដូលចិត្ត ៗ នាងនាថសោកសឹងសោក សែនអាមោកអួល អាណិត អនាថពន់ពេកក្កាត់ គិតដនទីទូរបិតា ៗ បន្ទោរទុក្ខ ស្រោលស្រេច ទើបសម្ដេចព្រះរាជា ទូរនាងនាថលុតលា វិលវិងមក មណ្ឌលទី ៗ ផ្ដែផ្ដាំអស់បរិពារ ស្រីស្រីង្គាស្នំនារី ទូរអស់មុខមន្ត្រី ដ្បិតទីងស្ដេចទៅទូរស្ថាន ៗ ស្ដេចឲ្យយកពាជី ជាព្រះទីនាំងក្សត្រ ក្សាន្ត ចងគ្រឿងសឹងមាសមាន ដំឡៃតតឯគណនា ៗ បង្ហៀរទូរឃុំមុខ ខ្សែរឹតអុកសឹងសុវណ្ណ អានជាប់មាសមុខា កយរំលេចសឹងមណីរត្ន ៗ ប៉ែកឈ្នាន់ខានដីបចង ចង្ក្រង់ផងសឹងពិចិត្រ ខ្សែហាងគុមកែវកិត ក្ដិរុងរឿងសមសោភា ៗ សំយាកសំយុងខ្សែ សោតសឹងតែសុវណ្ណ ល្អស្រលាយទែងទឹបជា ផ្កាដួងជាំសឹងកក់កាយ ៗ ទើបក្សត្រពីរព្រះអង្គ ប្រដាប់ទ្រង់គ្រឿងពណ្ណរាយ រុងរឿងឆោមឆើតឆាយ ល្អលើសលែង ទិព្វករ ៗ ស្ដេចសៀតព្រះទម្រង់ ខ័នជ័យទ្រង់ធ្នូសិល្បសរ នាំនាង នាថបវរ ចាកមន្ទីរមណ្ឌលថ្ងៃ ៗ

បទកាកគតិ

ក្សត្រក្សាន្តពីរពង្ស លីលាឡើងគង់ លើកជមនោម័យ ត្រចង់ ត្រចះ ល្អល្អះប្រពៃ ហាក់សុរិយោទ័យ ចរចូលចន្ទ្រា ៗ គួរគង់ បើកបរ ទីនាំងអស្សត្រ លន់លឿនលីលា ចេញចាកអំពី បុរីរដ្ឋា ផ្ដោះទៅសីមា ពាក់ណាសី ៗ ស្ដេចដោយមាគ៌ា ចូលក្នុងអដ្ឋា

ព្រៃព្រឹក្សទូទៃ លូតលាស់ស្លឹកផ្កា ផលាទុំខ្ចី មានរសពិសី ពិសេស
ពិសា ៗ ស្តេចដល់ព្រៃស្វាយ នាំនាងដោមដាយ ចរចុះយាត្រា
ព្រះនេត្រវៃត ទតព្រៃព្រឹក្សា សំណេះបរបា ប្រាប់ព្រះប្អូនស្រី ៗ
ប្អូនមាសប្រសើរ សូនអើយមាសមើល ស្វាយក្បាលដំរី ស្វាយដំពុះ
សេក ស្វាយបេកតន្ទ្រីយ ជិតស្វាយចន្ទី ដុះដោយពណ៌ក ៗ ប្អូន
មើលស្វាយមាស ស្វាយម៉ង់ដេរដាស មីងព្រសសែដា មាក់ព្រូន
ស្វាយព្រៃ ក្រាស់ក្រៃក្រៀបក្រា ទាំងស្វាយរំពា ស្វាយរមៀតផង ៗ
មានស្វាយបន្ទុះ ស្វាយកណ្តុរដុះ ដាសដោយផ្លែផង ស្វាយសង្ហើចម្អែះ
ស្វាយសេះពង់ត្រង់ ស្វាយខាន់ស្ករធង់ ឈ្មោកគន្ធូលាំ ៗ ខ្នុរទុំអន្ទង់
ខ្នុះជ្រុះបង់ទង ដោយដីដោកជាំ សេកសោកត្រួះត្រៀវ ឆ្វាខៀវ
នាំនាំ គ្នាហើរទៅតាំ ចុះបរភោគា ៗ ប្អូនមាសវរវង្ស មើល
ក្របមាក់ប្រុង សរមៃសំសា ក្របចិនក្របបង់ សក់ផងនានា ក្រប
ធារក្របភ្នា បើនពណ៌ពេកក្លាត់ ៗ មាសមើលក្របព្រៃ ជាតិដោរក្រៃ
នូវក្របពោធិសាត់ ផ្ទៃទុំនេទាល ព្រាសព្រាលបើនក្លាត់ នូវក្រប
ពោធិ៍សាត់ ក្របសើចក្រាស់ក្រៃ ៗ មានបេកអំបូង បេកឥតត្រយូង
នូវបេកមហាថ្ម បេកខ្នុរបេកស្នែង ដុះឯងវិស័យ បេកក្របកដៃ
នាងខ្លួនបេកថ្ម ៗ បេកកាដសីហ៍ ដុះដោយទួលទី បេកផេះមហា-ត្រ-
កាលបេកល័ក្ក បេកបាក់នានា បេកស្មាចមុខពក់ នូវបេកពង់មាន់ ៗ

ដេរដាសដោយព្រៃ ប្រុងប្រាងព្រឹនក្រៃ មានថ្ងៃណាណាន់ ទុំទេង រន្ទាល ប្រាសប្រាលព្រឹនផាន់ ដាផ្សារខែត្រចំណ្ណា ផុះដោយពណ៌ក ៗ ស្តេចទ្រដាយា បេះផលាហារ ដោយដងមាគ៌ា មង្ស្រតគូលែន ម៉ក-ប៉ែនតុក្រា ខ្ទរណាំងបាយស្រា លុងលុតពិលពៅ ៗ សាបសិរមាន់ មៀន ម៉កប្រាងទូរេន ដូងទុំះអំពៅ លាំងសាតសាវម៉ាវ បង្ការបង្កៅ ត្រៀលត្រែកត្លៅ សំពោចស្រគំ ៗ ពោនពួចឯទ្រុស គុយក្ងៀរព្រីង ព្រុស ផុះដោយព្រៃក្តំ ផ្ដៃព្រីនប្រាសប្រាល រន្ទាលទេងទុំ តិរក្សត្រ ឧត្តម ស្តេចសោយស្កប់ស្កល់ ៗ ស្រេចស្តេចឡើងគង់ លើយាន្ត-ម-ង្គលគាប់ស្នួស្ដិសល់ ត្រេចរចៀតទៅ សំដៅផ្លូវដល់ ពាលវែងយង់ យល់ សត្វសត្វនានា ៗ មើលមានគជសីហ៍ គជសិង្ហព្យគ្ឃ ក្រាស់ក្រៃ ត្រៀបត្រា កេសរកោតកុញ្ជរ កេសរសីហា ឧសឧដ្ឋផ្គុំភា-មិត្រមាំង គ្នាតស៊ី ៗ ព្រោះព្រៃរមាំង រមាសទ្វីងភាំង គោមៀមបាម៉ី កិលេន លៀងកា ស្នាន់លាពាង នរសិង្ហនរសីហ៍ ដំរីខ្មោងខ្លា ៗ ទន្សោង ទន្សាយ ទន្សោងឈ្លូសទ្រាយ គោមហិង្សា ចចកស្វាស្វាន ប្រើស ក្ដាន់ស្ទុកក ឆ្កែព្រៃលម៉ា ពង្រលលាក់មុខ ៗ លិសំពោច ឈ្លូសឆ្នាំប្រភេទ កន្ធែនកំប្រុក បង្គួយដាសស្ការ ពស់ប្ញានថ្ងៃនប្រុក វិហារស្រុក រកខ្លួនត្យនៅ ៗ ស្តេចយល់អម្រិត រកៀងគូគីក ស្រែកគីស្ទៅ បើកបរលេង ដល់ដងព្រៃព្រៅ យល់បក្សានៅ

បក្សីទាំងឡាយ ៗ ហិចហើរឆៀងឆាប ទន្ទេងទន្ទាប ទន្ទឹមរៀងរាយ
ដោយមែកព្រឹក្សព្រៃ ក្សត្រថ្ងៃពណ្ណរាយ បន្ទូលប្រាប់ប្រាយ ព្រះ
ប្អូនតាំងា ៗ ស្ងួនអើយមាសមើល បក្សាផងហើរ បង្ហើររៀងគ្នា
សេកសោមបណ្ឌិត នៃបទិត្យសារិកា កែវកោកិឡា កុកក្រកគ្រោង
គ្រេង ៗ ដបលាយសៀនយៀន ជជេតជើងទៀន រនេបព្រលេង
ប្រមង់ពញាក់ ទ្រមាក់ខ្ទះខ្វែង ស្ទាំងតាក់កន្ទ្រេង ដំដែកទុកទ្រ ៗ
សម្បុកទំពាំង ស្ទឹកលោតដាចស្បាំង ខែលខេងហូតូរ ចចាតច្រចៃឡ
ព្រាបព្រៃប៉ាគូ ករវែកស្រែកឈូរ ចាបតូកតូម៉ា ៗ មាសមើល
ហែមហង្ស មយូរពេនពង់ ចាក់ចាន់ផុល្ងកា ជីវកជីវាក គ្រៀល
ក្រាកក្រសា តាដក់អកអា-អូតឪឡុស្ទឹក ៗ ប្រចៀចចេកចុំ ចៀច
ក្រប៉ាសត្តុំ ពពូកពុះទឹក លលកលលេ រំពេប្រឹក មាន់ទោមាន់ទឹក
ស្មោញចង្កឹតខ្មៅ ៗ មាន់ព្រៃពស់វែក ត្រចៀកកាំក្អែក ប្រហិតស្វិតចៅ
ល្វាចេកប្រចៀវ ទៀទៀវតាវៅ ទីទុយមៀមខៅ ផ្ទីរចង្កៀលខ្យង ៗ
ក្ងានក្អែក ក្រប៉ាលក្រោក រនាលត្រយ៉ង សស្រេះសេះលាវ រងាវ
កកកង ក្រេងកុកត្រសង ត្រសិតហើរហិច ៗ នាងទូនក្អែកក្អាត
គូកគរលើងគ្នាត ត្រុំត្រដៀវវុិច កង្កួចសករ ចាកក្រពាកស្តេច-គោ
លិង្គប្រពេច ទុងទោមទទា ៗ បគាវចំនៅ អន្ទិតកុលជោ អង្កួចតន្ទ្រា
សេកយារសេកអាត់ ប្រេងក្អាត់ត្រៀចត្រា ក្ងូវក្ងូក ត្រឹបកេសរក្ស៊ ៗ

ស្តេចទតបណ្តើរ ដោយផ្លូវដំណើរ ប្រាប់ព្រះប្អូនស្រី ខែងទាំងបើកបរ
បវរពាជី ដល់ឆ្នេរជលធី ស៊ើសពក់ពុំជ្រៅ ៗ ស្តេចបវធ្លាស់ឆ្លង
សមុទ្ររម្លង ពីនោះទៀតទៅ យាត្រាត្រេចត្រង់ ដម្រង់សំដៅ
ដល់ស្រុកលំនៅ ឋានធម៌មាតា ៗ ពីរពង្សក្សត្រថ្លៃ ចុះចាកអាជានេយ្យ
ឡើងលើគ្រឹហា ជូនចាស់ស្រាក់ស្រួល សាកសួរក្សត្រា ស្តេចប្រាប់
ដោយនា ដំណើរការកល ៗ សុះសព្វសេចក្រេច ជូនចាស់ស្តាប់ស្តេច
អរឥតធ្ងឹមដល់ រួសរៀបអាហារ ភ័ស្តុការភោជន៍ផល ថ្វាយក្សត្រិនិមល
ទាំងពីរអង្គ ៗ ស្តេចសោយស្កប់ស្កល់ ផុំនោមណ្ឌល ឋានធម៌មាតា
លុះព្រឹកស្រាងស្រេច ស្តែងស្តេចលាកលា ត្រោះទៅចំការ ទីដែល
និត្យនៅ ៗ អ្នកស្រុកផងយល់ ក្សត្រថ្លៃនិមល នូវព្រះប្អូនពៅ
ទ្រង់គ្រឿងរន្ទាល ចាសប្រាលធ្លូនធ្លៅ គួរគង់ខែបនៅ លើសេះ
អាជានេយ្យ ៗ សឹងគន់គិតធ្ងល់ ថាបោរភោគកុល ទុគ៌តក្រក្រៃ
បានសេះពីឯណា សោភាប្រពៃ ទាំងគ្រឿងមាសវៃ ថ្លៃឥតគណនា ៗ
សឹងសរសើរសល់ ឮលេចដឹងដល់ តាមភោជកជាំ មេស្រុកកំណាច
គិតកាចឫស្យា ចាំចងវេក ទឹងព្រះពាជី ៗ ដើរមកមើលយល់
ក្សត្រថ្លៃនិមល នូវនាងនារី រលីងមកដល់ មណ្ឌលឋានទី បាន
ទាំងពាជី ទីនាំងថ្លៃថ្លា ៗ ទើបមេស្រុកទៅ ដល់ក្សត្រកម្លៅ
ព្រហ្មទត្តពាលា រិះរកកលគិត គំនិតមុសា-វាទរៀបទូលថា បពិត្រ

ក្សត្រថៃ ៗ គង្វាលនេះទៅ គោគកុលចេញទៅ បាត់យូរលង់ថ្ងៃ សម
ទៅអន្ទង ក្សត្រផងដៃ មកក្បត់ក្សត្រថៃ គិតពុំឃាតឃ្លា ៗ វិលមក
បានទាំង អស្សតរទ័នាំង បញ្ចុះភរិយា ខ្ញុំបានដើរទៅ យល់នៅចំការ
មើលបុកយល់ជា ប្រែចំគូទីទៃ ៗ បើព្រះអង្គ:ជាយ ប្រហែសអត់ឲ្យ
ទុកនៅក្នុងថ្ងៃ ក្រោមក្រែងក្រក្រោយ សូមឲ្យក្សត្រថ្ងៃ ផ្ចាញ់ពឲ្យក្ស័យ
ជីវិតទើបជា ៗ ស្តេចស្តាប់ទំនួល តាមគោជកទូល ត្រេកត្រាស់ទៅថា
យើងឲ្យទៅយក ហៅមកយល់ជា មាណពនោះវា ពុំមកជួបចិត្ត ៗ
បើឲ្យសេនា ទៅចោមចាប់វា សម្លាប់ជីវិត យល់ជាពុំបាន វាមាន
សិល្បសិទ្ធិ ចេះយើងទីងគិត ជួបម្តេចក៏ជា ៗ ទើបតាមគោជក ជា
ចៅមឿងស្រុក ទូលទៅទៀតថា បពិត្រព្រះអង្គ សូមទ្រង់ចិន្តា ឲ្យ
អស់សេនា បរពលទាំងឡាយ ៗ ទោះចិនចាមជ្វា បារាំងលន្តា
បរទេសសៃសាយ លើកទៅចោមចាប់ សម្លាប់ខ្ចាត់ខ្ចាយ កុំគិតមើល
ងាយ ប្រហែសនឹងវា ៗ

### បទពំនោល

កាលណោះព្រហ្មទត្តរាជា ស្តេចស្តាប់វាចា ពាក្យតាមគោជក
ក្រាបទូល ៗ ត្រើសត្រមព្រះទ័យជួបចូល ក្សណក្សត្រឥស្សូរ បន្ទូល
ត្រាស់ប្រើសេនា ៗ ចៅចេញបរពលកាសា ស្រុកទន្ទឹម្មា ឲ្យបានចូល
មកគាប់ ៗ ៗ អាមាត្យប៉ត់បាទស្ដែងស្ដាប់ ទទួលបង្គាប់ បង្គំប្រណម្យ

លុតលា ។ ចរចេញប្រាមប្រាប់គ្នា ទាហានអាសា យាត្រាប្រញាប់ប្រ
ពល ។ ប្រជាកស្ត្រុកងមណ្ឌល ខែត្រខណ្ឌសកល ពាកណាសំសោមា ។
ក៏កាន់គ្រប់គ្រឿងសស្ត្រា ចួតចងគាថា ប្រទាលកជះគុជគង់ ។ ពាក់
មួកពាក់អាវក្រោះផ្លង់ ប្រដាប់ការអគ្គិ ប្រយោជន៍ប្រយុទ្ធប្រឹងប្រាណ ។
ស្រេចចូលម៉ែម្ហូលមកថ្កាន ដល់មុខព្រះលាន ប្រកិតអារុជត្រៀបត្រា ។
កាលណោះព្រហ្មទត្តរាជា ស្តេចឲ្យយកបា ដំរីទាំងនិរភ័យ ។ ចង
គ្រឿងកញ្ចាំងមាសវៃ ភ្លឺផ្លេកប្រពៃ ពិចិត្រសឹងវត្ថុដាំដាក់ ។ ក្បាច់
ក្បាំងទង្គន់ខ្សែផ្ទាក់ ដងក្រពាត់ពាក់ ប្រភក់មាសមានរស្មី ។ ស្នាប់
មុខស្រោមក្លុកដំរី សឹងមាសមណី កន្ទេរសឹងវត្ថុរចនា ។ ស្តេចឲ្យ
រៀបពលយោធា ទាហានអាសា ចេញជាចតុព្យូហ៍យុទ្ធ ។ ស្រួចប៉ែក
ផ្លេងស្តាំមោះមុត ណាន់ណែនប្រាជក ប្រកបដោយលេខទីទៃ ។
សេនាកុមារនិរភ័យ សឹងកាន់ទង់ជ័យ បញ្ជូរបញ្ជូប់ត្រាត្រៀម ។
អណ្តាប់នោះសោតសឹងសៀម កាយរៀបមេរៀម ដាក់លើដំរីផ្គងផ្គួ ។
សេនាខ្មែរសឹងកាន់ធ្នូ បេះបាញត្រង់ត្រូវ មុតមែនកែនស្លាត់ជម្រង់ ។
អណ្តាប់នោះចិនហៃហុង រឹងរូសជ័ទ្រទង់ ក៏កាន់ដាវខ្វីស្រោងស្រោង ។
ប៉ែកស្តាំសោតសឹងបារាំង ក៏កាន់ស្នាប់ប៉ាំង ម្នោម្នះមហិមា ។
អណ្តាប់នោះសឹងគុល្ឡា កាន់សាមសែង្ហារ គ្រីពញ្ញមពន់ពេក ។
អណ្តាប់នោះសេនាខែក កាន់សេឡោស្បែក ទូរដារក្ងនស្រោលងោ ។

បែកភ្លេងសោតសឹងសេនា យួនយកអាសា ក៏កាន់កាំភ្លើងសុកកោង ៗ សេនាផ្គាគាំតក្រអោង ដូតក្បាលសំពោង ក៏កាន់នូវក្រើសគ្រប់ដៃ ៗ សេនាចាមចិនហាននៃក្រ កាន់កាំភ្លើងវែង បញ្ឈរប្រជែងប្រាជ្ញទទាស ៗ ទំពាហានលន្ទាស្អាតណាស់ កាន់មេសរព្រួស របៀបប្រាំបីសំពែង ៗ សេនាយីពុនខ្វះខែង ក៏កាន់ដាវវែង ត្រីគម្ពើនឃ្មារ ៗ អណ្ដាប់នោះសេនាលាវ កាន់លំពែងសារ តាមវិចងប៉ុនរន្ទាល ៗ សេនាមនទៅកណ្ដាល ដិតដើងគជសា គជេន្ទ្រទំនាំងក្សត្រា ៗ កាន់ស្នងក្របីងង៉ា ខ្លះកាន់គ្រឡា ខ្លះកាន់ដបខចាំបែរ ៗ ខ្លះកាន់តូរ្យតន្ត្រីត្រែ - សង្ខ័សីងដើរហែ អណ្ដាប់អណ្ដាយរៀងគ្នា ៗ ទើបក្សត្រព្រហ្មទត្តរាជា ទ្រង់ពារពស្ត្រា ប្រដាប់អស់អគ្គិតន្ទ្រីយ៍ ៗ ទ្រង់គ្រោះពេជ្ររត្នមណី ឡើងគង់ដំរី ទីនាំងបើកប៉ាំងក្លស់ក្ងំ ៗ ស្ដេចឲ្យដំរីសាសម រូបរាងឆាត់ធំ ចុះប្រែងហួរហៀរងល់ក្លុក ៗ ដាក់ឲ្យទៅតាមភោជក ដំរះបរនាំមុខ ទីនាំងព្រះបាទក្សត្រា ៗ ស្ដេចលើករេហ៍ពលយោធា ឆ្ពោះត្រង់ចំការព្រះពោធិសត្វនិម៌ល ៗ ដល់ស្រែបស្ដេចឲ្យអស់ពល ហោមជុំមណ្ឌល ប្រាំពីរជាន់ជិតត្រៀបត្រា ៗ ហោរហាខ្វរខ្វាររមហិមា ទើបស្ដេចត្រាស់ថា ហៃចៅភោគកុលកុមារ ៗ ចៅនាំកិរិយាត្រអាល ចេញទៅគិតការគំនិតនឹងក្សត្រដទៃ ៗ ចៅយកទ្រព្យមានដំឡៃ ទៅថ្វាយប្រស័យ យិតយោងអន្ទងមកក្បត់ ៗ យើងមានដំរីច្រកជ យើងនឹងធ្វើគត់

សម្លាប់ចោលនេះឥឡូវ ៗ ដ្បិតចោលចេញជាស្រូវ ពុំគួរទុកនៅ ឲ្យរស់
ជីវិតជន្មា ៗ កាលណោះព្រះពង្សត្ថា ស្តែងស្តាប់ថា ស្តេចព្រហ្ម-
ទត្តទិដ្ឋ ៗ ព្រះអង្គឥតភ្លឹកភ័យពី សឹកដូចកេសរី សីហាខាំចេញចាក
គូហា ៗ មានព្រះបន្ទូលទៅថា រីឯក្សត្រមោហា អង្គអន្ធពាលឆោត
ឆុត ៗ ដោយតែពាក្យគាម.ភាជក នាំទៅនរក ពុំគិតបាបពៀរវេរា ៗ
រកកលទឹងធ្វើទោសា ឲ្យយើងមរណា ទឹងយកភរិយាយើងទៅ ៗ
ទាល់តែនាងនាងពុំនៅ រត់រំលងទៅ ដល់ព្រះបិតាក្សត្រក្សាន្ត ៗ
យើងត្រូវទៅតាមព្រួយប្រាណ យកនាងមកបាន អំពីព្រះវរបិតា ៗ
ឥឡូវលើកពលយោធា មកចោមប្រាប្ដា បង់ចាប់សម្លាប់យើងទៀត ៗ
រកកលមុសាផ្លាស់ផ្លៀត ថាយើងបោរបៀត ចូលទឹងស្រូវដៃ ៗ
ចូរចេញចយទៅវៃ ៗ បេខំនៅក្បែយ ព្រះឯនុត្តឡូវនេះច្បាត់ ៗ កាល
ណោះព្រះបាទព្រហ្មទត្ត ស្តាប់ហើយក្រោធក្តាត់ ថាព្រះអល់ពល-
យោធា ៗ ចូរចោមចាប់យកតួវ មកកាត់សិរសា ឲ្យបានឥឡូវឆាប់ៗ ៗ
អស់អង្គសេនាស្តែងស្តាប់ រត់ចូលប្រញាប់ តាមដោយព្រះពជអាជ្ញា ៗ
ឯអង្គព្រួងពង្សសាស្តា គតភិតភយា ស្តេចយកព្រះកៅទ័ណ្ឌជ័យ ៗ
ទលាក់ដំឡើងវាត់វៃ ព្រះហស្តក្សត្រថ្លៃ ថ្លែងថ្វាត់បន្ទោះចេញទៅ ៗ
លានព្រុកក្រើកក្រៀលក្រៅ ទួទាំងលំនៅ កណ្តាប់នៃចក្រវាឡ ៗ
ដូចសែនរន្ទះមហិមា បាញ់ចុះព្រមគ្នា ហាក់ដូចទឹងផ្លាប់ប្រិថពី ៗ

ពុះពោរជន់ជោរជលធី សុមេរុគិរី ក៏ក្រើករំពើកពេកក្លាត់ ៗ កាលណោះឯអគ្គមហាក្សត្រ ព្រះបាទព្រហ្មទត្ត នូវគាមកោដកអប្រិយ៍ ៗ ភិតធ្លាក់ពីលើដំរី ដួលដល់ផែនដី ក្សិណក្ស័យជីវិតជន្មា ៗ ធ្លាក់ទៅសោយទុក្ខវេទនា នៅនរកមហា-តាបដល់កន្ទុះកល្បគត់ ៗ អស់ពលផងភិតរន្ធត់ ស្ញើតស្ញាំងស្ងន់ស្ងុត ដួលដេកនទៀលត្រៀបត្រា ៗ អស់មុខមន្ត្រីឯណា ដែលគិតនឹងមហា-ក្សត្រាសឹងក្ស័យជីវិត ៗ ឯណាពុំបានបួលគិត មូលមួយគំនិត ក៏សឹងរួចរស់ជន្មា ៗ ក្រោកឡើងញ័រអស់អង្គា ភិតភ័យតក្កមា បង្គំប្រណម្យទូលទៅ ៗ បពិត្រអម្ចាស់ចមពៅ សូមទានទ្រង់នូរ-មេត្តាករុណាអត់ទោស ៗ ឲ្យទានជីវិតសន្តោសអាសូរប្រាណប្រោស ឲ្យគង់ជាខ្ញុំតទៅ ៗ ទើបព្រះពូជពង្សពុទ្ធទៅបើកបន្ទូលទៅ ថាហៃអស់មុខមន្ត្រី ៗ គ្រប់គ្នាតើមានទោសអ្វី កុំភ័យទៅប៉ី អញសោតពុំយកទោសា ៗ មន្ត្រីត្រេកអរគ្រប់គ្នា ដ្បិតស្ដេចមេត្តាប្រោសទុកជីវិតឲ្យគង់ ៗ ទូលថាបពិត្រព្រះអង្គ អម្ចាស់ថ្លៃទ្រង់ ព្រះ-គុណព្រះករុណាណាស់ ៗ ឥតអ្វីផ្ទឹមគុណក្រៃក្រាស់ អញ្ជើញអម្ចាស់ទាំងពីរទៅសោយរាជ្យរម្យ ៗ ជាឥស្សរអស់យើងខ្ញុំ គ្រងផ្ទៃក្រោមក្រំពិភពពិភ័ក្តិស្ត្រផង ៗ

**(នៅមានត)**

ពន្លឺ អាស៊ីទ្វីប

# លោកវ៉ាយ-ប៊ុក ក្រមការ រៀបរៀង

(តមក)

---

គ្រានោះ ព្រះរាជស្វាមីត្រាស់ថា "ឱ ! ព្រះនាងថ្មើមថ្លៃ រឿងការទាំងនេះ ល្អមើលណាស់" ។

ព្រះនាងក្រាបទូលតទៅទៀតថា "ក្សត្រថ្លៃខ្ញុំម្ចាស់អើយ, តអំពីសុបិននេះទៅ ខ្ញុំម្ចាស់បានឮសូរសំឡេងមួយគួរឲ្យស្ញប់ស្ញែងស្រែកថា "ពេលជិតដល់ហើយ ! ពេលជិតដល់ហើយ ! រួចតមកខ្ញុំម្ចាស់បានឃើញសុបិនទី ៣ ហាក់ដូចខ្ញុំម្ចាស់មានបំណងចង់ប៉ះពាល់ព្រះអង្គម្ចាស់ថ្លៃខ្ញុំអើយ នៅលើក្រឡាបន្ទំខ្ញុំម្ចាស់បានឃើញតែរងព្រះសិរស្អាតតមន្ទិល នឹងព្រះភូសាភាសារប៉ុណ្ណោះ ប៉ុន្តែតព្រះអង្គគង់នៅសោះ !- គឺតព្រះអង្គទុកដូចជាប្រទីប ជាដួងជីវិត ជាក្សត្រជាបក្រាឡ របស់ខ្ញុំម្ចាស់! ខណៈនោះរបស់ទាំងអស់ស្ងប់ស្ងាត់ស្ងៀប ខ្ញុំម្ចាស់បានក្រោកឡើងបានឃើញខ្ទឹមខាតប្រដាប់ត្បូងមុក្តារបស់ព្រះអង្គនៅទីនោះ ក្រពត់កាយខ្ញុំម្ចាស់ ស្រាប់តែក្លាយទៅជាពស់មួយ បែរមកចឹកខ្ញុំម្ចាស់វិញ កងព្រះបាទខ្ញុំម្ចាស់ក៏ធ្លាក់ជ្រុះទៅដី កងបូរៃទ្រមាសក៏បាក់ដាច់ខ្ទេចខ្ទី ផ្កាម្លិះដែលក្រងប្រដាប់ ព្រះកេសាក៏ជ្រុះរត់រាយអស់ទៅ ព្រះទែនសេយ្យនា ក៏ត្រឡប់បាក់អស់ ព្រះសន្ទិយាក៏រហែកដាច់ដាច ៗ គ្រានោះ

ខ្ញុំម្ចាស់បានឮសូរសម្រែកគោទស្រុកពងស នោះពីចម្ងាយ បន្ទាប់ពីនោះ ខ្ញុំម្ចាស់បានឃើញទង់ជ័យប៉ាកនោះបក់រវិច ហើយឮសូរសម្រែកដូចមុននោះទៀតថា "ពេលមកដល់ហើយ! ៗ សម្រែកនេះ ធ្វើឲ្យវិញ្ញាណខ្ញុំម្ចាស់រំភើបញាប់ញ័រនៅឡើយ ៗ ឱ ក្សត្រថ្លៃម្ចាស់ខ្ញុំអើយ! តើសុបិននេះប្រែសេចក្ដីដូចម្ដេច បើតាមខ្ញុំម្ចាស់យល់ គឺថាខ្ញុំម្ចាស់នឹងសោយព្រះវិលាល័យ ឬមិនដូច្នោះទេ ព្រះអង្គនឹងប្រាសបង់ចោលខ្ញុំម្ចាស់ទៅ ឬត្រូវស្ដេចចាកចេញពីព្រះរាជឋាន ?"

ព្រះសិទ្ធត្ថរាជកុមារទ្រង់ទតព្រះនេត្រទៅកាន់ព្រះរាជទេពីដែលកំពុងទុក្ខព្រួយ ដោយព្រះទ័យមេត្តាប្រណី ហាក់ដូចព្រះសុរិយាសំដែងអាការញញឹមមុនអស្ដង្គតទៅ ហើយទ្រង់មានព្រះបន្ទូលថា "ទេវីសំឡាញ់, កុំព្រះនាងព្រួយចុះ បើទុកជាសុបិនព្រះនាងអាចក្លាយទៅជាមានពិតទៅអនាគតក្ដី ទុកជាពួកទេវតាគង់លើអាសនាមិនបានសុខស្រួលក្ដី ពិភពលោករកបុគ្គលណាមួយជួយដោះទុក្ខគ្មានក្ដី ទោះបីជោគវាសនាប្រែប្រួលទៅជាដូចម្ដេចក្ដី ក៏សូមឲ្យព្រះនាងជឿទុកចិត្តចុះថា ពីមុនព្រះជេដ្ឋាស្រឡាញ់ព្រះនាងយសោធរាយ៉ាងណា ឥឡូវក៏នៅតែស្រឡាញ់ព្រះនាងយសោធរាយ៉ាងនោះដែរ ៗ សូមឲ្យព្រះនាងជ្រាបថា ព្រះជេដ្ឋាមានបំណងច្រើនខែមកហើយ ដើម្បីស្វែងរកមធ្យោបាយជួយស្រោចស្រង់ ពិភពលោកដែលប្រកបដោយទុក្ខលំបាក ដែលព្រះ

ដេដ្ឋាបានឃើញមកហើយ ហើយពេលវេលានោះមុខជានឹងមកដល់ខាន មុខមិនខាន ការដែលត្រូវប៉ះពាល់ក៏ខានពុំបាន ៗ ប៉ុន្តែបើហាប៉ុខយ៉ព្រះដេដ្ឋាព្រួយលំបាកចំពោះទុក្ខទោសដែលមិនមែនជារបស់ខ្លួនទេ សូមឲ្យព្រះនាងជ្រាបចុះថា ព្រះចិន្តារបស់ព្រះដេដ្ឋាហោះហើរអណ្តែតទៅលើសព្វសត្វមានជីវិតទាំងអស់ ដោយសេចក្តីមេត្តាប្រណីគ្មានទីបំផុតពិតមែនហើយព្រះនាងជាទីស្រឡាញ់ពេញចិត្តព្រះដេដ្ឋាណាស់ ព្រះនាងគួរបាប់ចិត្តស្នេហាបំផុត, ប្រសើរបំផុត, នៅជិតបេះដូងព្រះដេដ្ឋាជាបំផុត ៗ អាហ៍! ព្រះនាងនេះហើយ ជាព្រះមាតារបស់ឧរសេដេដ្ឋា ព្រះនាងនេះហើយបានរួមកាយចិត្តជាមួយនឹងព្រះដេដ្ឋា ប៉ុន្តែព្រះទ័យព្រះដេដ្ឋាបានក្រាលគ្របសព្វផែនដី នឹងសត្វសមុទ្រ - ពោរពេញដោយសេចក្តីមេត្តាករុណាផ្សាយទៅកាន់មនុស្សលោកទួទៅ ប្រៀបដូចមេព្រាបស្លុះហើរយ៉ាងលឿនទៅលើអាកាស តែងមានចិត្តទន់ទៅកាន់សំបុករបស់វាដែលមានកូនតូច ៗ ហើយតែងវិលមករកសំបុកវិញជានិច្ច ត្រង់ជាងស្វាបយ៉ាងរីករាយដោយសេចក្តីស្នេហា ៗ ចំពោះព្រះនាងវិញ ដែលជាស្ត្រីប្រសើរបំផុត ជាស្ត្រីគ្រប់លក្ខណ៍ទន់ភ្លន់ណាស់ ជាស្ត្រីដែលទុកដូចជាអង្គព្រះដេដ្ឋាពិតប្រាកដ ៗ បើមានហេតុកេងទៅអនាគតដូចម្តេចសូមឲ្យព្រះនាងនឹករលឹកដល់គោឧសភរាជដែលស្រែកពេទ័រពង នឹងទង់ជាយដែលរេចរាដោយពេជ្រផ្ទិលចិន្តា ត្រូវព្រះពាយបកផាត់រំពេច ដូចមាន

ក្នុងសុបិនព្រះនាង ហើយសូមព្រះនាងជឿចុះថា ព្រះជេដ្ឋាស្រឡាញ់ពេញចិត្តព្រះនាងយ៉ាងណា ដល់មកឥឡូវនេះ ក៏នៅតែស្រឡាញ់ពេញចិត្តនឹងព្រះនាងជានិច្ចយ៉ាងនោះដែរ ហើយរបស់ដែលព្រះជេដ្ឋាខំស្វែងស្វះរកសត្វអន្ទើ ជាប្រយោជន៍ចំពោះព្រះនាងជាមុនបង្អស់ ។ ប៉ុន្តែព្រះនាងត្រូវបន្ទោបង់ទុក្ខសោក ដោយនឹកថា សន្តិភាពនឹងមានមកក្នុងលោកដោយសារសេចក្ដីនឿយព្រួយរបស់យើង ហើយចូរព្រះនាងសំដែងសេចក្ដីស្នេហាស្មោះត្រង់ ទទួលអំណរត្រេកអរ ព្រមទាំងព្រះពរសព្ទសាធុការ ។ របស់អស់នេះ មិនសូវប្រពៃថ្លៃថ្លាប៉ុន្មានទេ ព្រោះកំឡាំងសេចក្ដីស្នេហានៅទន់ខ្សោយណាស់ ចូរព្រះនាងចុម្ពិតព្រះទស្សព្រះជេដ្ឋា ហើយក្រេបផឹកនៅសំដីវាចា ដែលហូរចេញពីដួងហឫទ័យនៃព្រះជេដ្ឋា ដើម្បីឲ្យព្រះនាងជ្រាបថា ជនដទៃទៀតល្ងិតល្ងង់ឥតដឹងអ្វីសោះ គឺថាព្រះជេដ្ឋាស្នេហាចំពោះព្រះនាងក្រៃលែងជាងសត្វលោកដទៃទៀតទាំងអស់ ។ ព្រះជេដ្ឋាបង់ក្រោកឡើងពិចារណាហេតុការណ៍ទាំងឡាយ, ម្នាលក្សត្រី សូមឲ្យព្រះនាងគង់នៅទីនេះសិនចុះ ។

ម៉្លោះហើយ ព្រះនាងក៏ទ្រង់ព្រះកន្សែងផ្ទុំលក់ទៅទាំងទឹកខ្សែលអួលអាក់ក្នុងព្រះចិន្តា ពីព្រោះព្រះនាងយល់ព្រះសុបិនដូចមុនប្រាកដជាក់ស្ដែង ហើយបានឮពាក្យដូចមុនម្ដងទៀតថា "ពេល ! ពេលមកដល់ហើយ !" ប៉ុន្តែព្រះសិទ្ធត្ថរាជកុមារ ទ្រង់បែរព្រះភក្ត្រចេញពីព្រះនាង

ហើយក្នុងពេលនោះ ព្រះចន្ទ្របញ្ចាំងរស្មីភ្លឺខែង ហើយដួងតារាទាំងឡាយមានពន្លឺដូចប្រាក់ សមដូចពាក្យទំនាយដែលទាយទុកមកយូរហើយ ហាក់ដូចប្រាប់ថា "ពេលនេះ ជាពេលរាត្រី ចូរព្រះអង្គជ្រើសរើសយកផ្លូវចូលចំណើររឿង ប្អូនសប្បុរសចិត្តល្អ : ចូរព្រះអង្គជ្រើសយកផ្លូវសោយរាជសម្បត្តិជាចក្រពត្តិ ឬភាពជាអ្នកត្រេចរង្កាត់ទៅតែឯកឯង តតមកុដរាជ្យ តតប្រាសាទរាជដ្ឋាន ដើម្បីជួយសង្គ្រោះសាកលលោក" ។ ក្នុងវេលាគ្រានោះ ព្រះពាយរំភើយផាត់ក្នុងរាត្រីងងឹតខ្សឹបដាក់ព្រះកាណ៌ព្រះអង្គ នឹងដំបូន្មានដែលពួកទេវតាបានពោលជាសតៀនតាមសូរស័ព្ទខ្យល់ ហើយមានពួកទេពនិករហោមរោមជុំវិញព្រះជាម្ចាស់នៃយើង ដែលទ្រង់កំពុងពិចារណាដួងតារាដ៏ត្រចះត្រចង់ ។

ព្រះអង្គត្រាស់ថា "ខ្ញុំចង់ចេញទៅឥឡូវ, ពេលម៉ោងដល់ហើយ ! នក្សត្រីជាទីស្នេហា, បបូរព្រះឱស្ឋដ៏ទន់ភ្លន់ នាំឲ្យព្រះជេដ្ឋាប្រាថ្នានឹងជួយស្រោចស្រង់ពិភពលោក ប៉ុន្តែយើងត្រូវតែព្រាត់ប្រាសគ្នា ហើយខណៈដែលមហាមេឃស្ងប់ស្ងាត់នេះ ព្រះជេដ្ឋាកំពុងពិនិត្យដោតកក់ស្នាក្នុងលិខិតទាំងឡាយយ៉ាងចំពែង ។ ព្រះជេដ្ឋាមានព្រះបំណងនឹងត្រេចទៅកាន់ផ្លូវដែលត្រូវត្រេច អស់យប់ខ្វែងជាច្រើនមកហើយ ពីព្រោះព្រះជេដ្ឋាមិនត្រូវការមកុដរាជ្យ ដែលនឹងបានជារបស់ខ្លួនទេ ទាំងមិនព្រមនៅគ្រប់គ្រងរាជអាណាចក្រ ដែលរង់ចាំទទួលព្រះខ័នរាជ្យរបស់ព្រះ

ជេដ្ឋា កងវង់របស់ព្រះជេដ្ឋាទីងមិនវិល ដោយមានការកង់ប្រឡាក់ឈាម
ដោយការមានជ័យជំនះរឿងៗទៅ ដើម្បីឲ្យផែនដីរក្សាកត្តិនាមទុកជាអនុ-
ស្សាវរីយ៍ មានពណ៌ក្រហមឆ្អៅ ៗ ព្រះជេដ្ឋាពេញចិត្តប្រើជើងត្រេច
ទៅតាមផ្លូវដើង ឥតមានមោះមៃសៅហ្មង យកផែនដីជាព្រះទែនបន្ទំ
យកកំពូលខ្សាច់ដែលហោបានជាប្រាសាទដំណាក់ ទីងវត្ថុហ័នភាពទាំងឡាយ
ជាមិត្រ មានសំលៀកបំពាក់ដូចពួកមនុស្សគ្មានវណ្ណៈ មានភោជនាហារ
បានមកពីអ្នកស្រុក ដែលមានចិត្តជ្រះថ្លាធ្វើបុណ្យ ឥតលំនៅអ៊ីក្រៅពី
គុហាងងឹត ឬកំពោតព្រៃភ្នំទូតំម ៗ នេះឯងហើយដែលព្រះជេដ្ឋាត្រូវ
ធ្វើ ពីព្រោះស្នូរសៅម្រែកគួរអាណោចអាធម្មនៃជីវិតនិងពួកសត្វមានជីវិតទូ
ទៅ ផ្ទាបដល់ព្រះកាណ៌ព្រះជេដ្ឋៈទាំងអស់ ហើយដួងហឫទ័យនៃ
ព្រះជេដ្ឋាញុះពោរដោយមេត្តាករុណា ចំពោះទុក្ខសោកនៃពិភពលោក
ដែលត្រូវតែជួយសង្គ្រោះនេះ ដោយវិធីលះបង់ដាច់ខាត និងការតទល់
ដាច់ស្រេចចំពោះអាសវកិលេស ៗ ឯពួកទេពនិករទោះមានសក្តិធក្តិសក្តិ-
តួបក្តីតើអង្គណាខ្លះដែលមានអំណាចហើយមានចិត្តមេត្តាអាណិត (ចំពោះ
សត្វទាំងនេះ)? - តើអ្នកណាបានឃើញពួកទេពនិករទាំងនោះ? - ហើយ
ពួកទេពទាំងនោះបានជួយស្រោចស្រង់ ពួកជនដែលគោរពបូជាខ្លួនដូច
ម្តេច ? - តើបានៈធ្វើប្រយោជន៍អ្វី ដល់មនុស្សដែលសូត្រធម៌, ដែលបាន
ធ្វើពលីការដោយគ្រាប់ល្ងសណ្តែកនិងប្រេង, ដែលសូត្រមន្តគាថាអាគម,

ដែលបង្ហាញដោយជីវិត, ដែលកសាងព្រះវិហារយ៉ាងសំបើមថ្លៃថ្លា ថ្វាយ, ទំនុកបំរុងពួកសង្ឃ ហើយដែលទំបន់ស្រន់បួងសួងដល់ព្រះវិស្ណុ ព្រះសិវៈ, ព្រះសុរិយៈ ដែលគ្មានជួយអ្នកណាមួយឲ្យផុតចាកទុក្ខទោស ដល់មួងសោះ? តើមានបងប្រុសខ្ញុំណាមួយ, ដោយសារប្រតិបត្តិតាម ទំនងនេះ បានរួចរបូតចាកទុក្ខសោកក្នុងជីវិត, សេចក្ដីលំបាកដ៏ជូរចត់នៃ សេចក្ដីស្នេហា និងការព្រាត់ប្រាស់ចាករបស់ដែលជាទីស្រឡាញ់, គ្រុនរោគដែលធ្វើឲ្យកាយចិត្តរន្ធត់ញាប់ញ័រ, មរណៈដែលគួរស្អប់ស្អែង, សត្វសង្ខារតែងវិលជុំវិញក្នុងនៃសំសារចក្រ ហើយភពថ្មីតែងធ្វើឲ្យកើត ទុក្ខថ្មីទៀត, ការតពូជពង្សវង្សត្រកូលថ្មីជាអំពើបំពេញចំណង់ថ្មី ដែល បង្កើតឡើងជំនួសចំណង់ចាស់ដែលរលត់ទៅ? តើមានបងស្រីខ្ញុំណាមួយ បានទទួលផលអ្វីនៃការអត់អាហារ ឬការសូត្រមន្តការនោ, តើនាងបានផុត ពីទុក្ខលំបាកពីការប្រសូត្របុត្រ ដោយសារការបូជាទឹកដោះគោសសុទ្ធ ឬដោយការបូជាសំពត់ប៉ាក់ស្លឹកតុលសី ក៏គ្មានសោះ! ពិតមែនពួកទេព្តា ខ្លះល្អខ្លះអាក្រក់ ប៉ុន្តែសុទ្ធតែខ្សត់ខ្សោយអានុភាព • ពួកទេព្តាអស់នោះ ខ្លះក៏មានមេត្តា ខ្លះក៏កាចសាហាវ ហើយទាំងអស់នោះ ក៏ដូចជាមនុស្ស លោកដែរ តែងជាប់នៅក្នុងសំសារចក្រ ហើយវិលកើតវិលស្លាប់គតស្រាក ពីព្រោះព្រះគម្ពីរបានប្រដៅដោយត្រឹមត្រូវទុកថា កាលណា បើជីវិតចាប់មានឡើងហើយទោះបីជីវិតកើតពីដើមចមអ្វីឬពីហេតុអ្វីក៏ដោយ

តែនៅតែត្រូវបណ្តែតក្នុងវដ្តសំសារ ចាប់តាំងពីបរមាណូទៅដល់បាណក សត្វ, ដង្កូវ, សត្វលូនវារ, ត្រី, សត្វស្លាប, សត្វមានរោមលើរាងកាយ ហើយដរាបមកដល់មនុស្ស, ភូតបិសាច, ទេវតា, ព្រះព្រហ្មតែងវិលចុះមកកើតនៅផែនដីទៀត ហេតុដូច្នេះ សព្វសត្វទាំងអស់សុទ្ធតែជាសាច់ញាតិជាតិជាមួយ ប្រសិនបើគេជួយសង្គ្រោះមនុស្សឲ្យផុតពីការអន្ទោលនេះទៅបាន ពិភពលោកទាំងមូលនឹងបានភ្លឺទេង ចេញចាកអំពីអវិជ្ជាដែលគួរស្អប់ស្អែងនេះបាន ដែលមានសេចក្តីខាចជាស្រមោលនឹងការកំណាចឃោរឃៅជាគ្រឿងកំសាន្ត, អើមែន, ប្រសិនបើមានអ្នកណាមួយអាចជួយសង្គ្រោះពិភពលោកបាន ហើយវិធីនេះគង់តែមាន ទំពឹងពំនាក់របស់លោកត្រូវតែមាន ! មនុស្សទាំងឡាយតែងស្លាប់វិនាសដោយខ្យល់រងាត្រជាក់ តមកទើបមានអ្នកចេះដំបូចឲ្យកើតជាផ្កាភ្លើងឡើង ៗ មនុស្ស ( ពីដើម ) ស៊ីតែសាច់សត្វដូចជាសត្វបចក តមកទើបមានអ្នកព្រោះសាបស្រូវសាលីដែលដុះឡើងដូចជាស្មៅធម្មតា ហើយដល់មកឥឡូវនេះអាចចិញ្ចឹមមនុស្សលោកឲ្យរស់នៅបាន ៗ មនុស្សទាំងនោះខំប្រឹងញាក់មុខមាត់ហើយខំពោលពាក្យឡើង ទាល់តែកើតជាភាសា ១ ប្រឌិតឲ្យមានពាក្យសំដីឡើង ហើយម្រាមដៃខំហាត់សរសេរ ទៅជាលាយលក្ខណ៍អក្សរបញ្ចេញសូរស័ព្ទផ្សេងៗ ៗ តើបងប្អូនខ្ញុំបានទទួលអំណោយអ្វីខ្លះដែលកើតមកពីការស្វះស្វែងការអត់ធ្មត់នឹងការបូជាយ័ញ្ញដោយចិត្តស្មោះ

ត្រង់ៗ បើដូច្នេះ បើមានមនុស្សម្នាក់ដែលមានរិទ្ធិអំណាច មានគេរាក់ស្នា មានភោគសម្ប័ទ មានសុខភាពបរិបូណ៌ មានសេចក្ដីរីករាយក្រេមក្សាន្ត ដែលសមគួរនឹងសោយរាជសម្បត្តិ នឹងបានជាស្ដេចចក្រពត្តិ ប្រសិនបើមានមនុស្សម្នាក់មិនមែនជាចាស់ជរា ដោយមានអាយុច្រើន ប្រកបដោយសេចក្ដីសប្បាយរីករាយ តាំងនៅក្នុងបឋមវ័យ ; មិនមែនជាអ្នកឆ្អែតស្កប់ស្កល់ដោយលោកាមិស គឺជាអ្នកនៅស្រេកឃ្លាននៅឡើយ ; ប្រសិនបើមានមនុស្សមួយមិនមែនចាស់ស្បែកជ្រីវ មានទុក្ខព្រួយគឺជាអ្នកសប្បាយរីករាយនៅក្នុងជោគជ័យនឹងការសប្បាយលាយឡំដោយអំពើអកុសលក្នុងលោកនេះ មានសិទ្ធិជ្រើសរើសយកតាមចិត្តនូវវត្ថុដែលខ្លួនស្រឡាញ់ពេញចិត្តនៅលើផែនដី ជាបុគ្គលមួយ ដូចជារូបព្រះជេដ្ឋានេះ គត់ទុក្ខព្រួយ គត់ត្រូវការអ្វី តែមានសេចក្ដីព្រួយចំពោះសេចក្ដីព្រួយរបស់ជនដទៃ គត់មានទុក្ខព្រួយអ្វីក្រៅពីមនុស្សជាតិទេ បុគ្គលបែបនេះបើត្រូវការឲ្យក៏ឲ្យទាំងអស់ហ៊ានលះបង់ដោយសេចក្ដីមេត្រីចំពោះមនុស្សទាំងឡាយ ហើយប្ដូរជីវិតខ្លួនឯងទៀត ដើម្បីស្វែងរកសេចក្ដីពិត ទោះបីមនុស្សនោះទៅលាក់ខ្លួនពួននៅក្នុងនរក ឬក្នុងឋានសួគ៌ ទោះបីមនុស្សនោះលួងទៅនៅក្បែរយើងក្ដី ទោះបីនៅឆ្ងាយណាស់មិនដឹងជាពេលណា ឬ យ៉ាងដូចម្ដេចក៏ដោយ សំពត់ដែលបង់បិទភ្នែកក៏ត្រូវបើកចេញឲ្យក្ដីខ្វែងផ្លូវនឹងបើកទៅមុខ សម្រាប់ដើរដែលបុរេពង មុខជាគេនឹងទៅដល់

គោលបំណង គឺការបោះបង់ចោលនូវសម្បត្តិមហាចក្រក្នុងលោក ហើយ ស្ដេចមកប្រជុំមុខជានឹងបានជួបចៅហ្វាយរបស់ខ្លួន ៗ អំពើនេះហើយដែល ព្រះជេដ្ឋាប្រឹងនឹង ធ្វើ ព្រះជេដ្ឋាត្រូវបោះបង់ព្រះរាជអាណាចក្រមួយព្រះ ជេដ្ឋាមានបំណងដូច្នេះ ពីព្រោះព្រះជេដ្ឋាស្រឡាញ់អាណាចក្ររបស់ ព្រះជេដ្ឋា ពីព្រោះបេះដូងព្រះជេដ្ឋារន្ធត់ញាប់ញ័រ ជាមួយនឹងបេះដូង របស់សត្វឯទៀតដែលទុក្ខព្រួយទាំងអស់ ទាំងដែលស្គាល់ ទាំងដែល មិនស្គាល់ បណ្ដាសត្វលោកពប់លានកោដិដែលជារបស់ព្រះជេដ្ឋា ឬ ដែលនឹងត្រូវបានជារបស់ព្រះជេដ្ឋាសឹងត្រូវព្រះជេដ្ឋាជួយស្រោចស្រង់ ដូចគ្នាទាំងអស់ក្នុងកាលឥឡូវនេះ ៗ ឱដួងតារាជាទីប្រិយាទាំងឡាយ, ឥឡូវខ្ញុំមកហើយ! ឱផែនដីដែលរងតែទុក្ខទោស! ឥឡូវខ្ញុំលះបង់នូវ សេចក្ដីសប្បាយក្នុងបឋមវ័យ, នូវរាជបល្ល័ង្ក នូវសេចក្ដីរីករាយ នូវសេចក្ដី រុងរឿងទាំងយប់ទាំងថ្ងៃ, នូវសេចក្ដីក្រេមក្សាន្តក្នុងព្រះរាជវាំង នៃព្រះ-អគ្គមហេសីសម្លាញ់, ព្រះហត្ថាព្រះនាង ធ្វើឲ្យព្រះជេដ្ឋាលំបាកនឹងលះ បង់ជាងវត្ថុដទៃទៀតទាំងអស់ ៗ ប៉ុន្តែព្រះនាង ក៏ត្រូវព្រះជេដ្ឋាជួយ ស្រោចស្រង់ នៅពេលដែលជួយសង្គ្រោះពិភពលោក ៗ ទារកដែល-នៅក្នុងព្រះឧទរព្រះនាង គឺបុត្រសំឡាញ់របស់ព្រះជេដ្ឋា ដែលជាផ្កាជា ទីស្នេហារបស់យើង ដែលអាចនឹងធ្វើបំណងរបស់ព្រះជេដ្ឋាឲ្យទន់ខ្សោយ ទៅ ប្រសិនបើព្រះជេដ្ឋាចាំបីបមថ្នមពារ ឱព្រះទេពី! ឱកូនឪពុក!

ឱព្រះវររាជបិតា ! ឱពួកប្រជាជន ! ត្រូវអ្នកពល់គ្នាទាំងទទួលសេចក្ដីព្រួយលំបាក ក្នុងរយៈវេលាមិនយូរប៉ុន្មានទេ មុខជាមានពន្លឺដ៏ភ្លឺច្បាស់ ហើយសត្វលោកទាំងអស់នឹងបានសិក្សាព្រះធម៌ ។ ឥឡូវនេះ ខ្ញុំបានដាច់ចិត្ត ខ្ញុំនឹងចេញទៅ ហើយនឹងមិនបានវិលមកវិញ មុនបានជួបប្រទះរបស់ដែលខ្ញុំត្រូវការស្វែង ប្រសិនបើការព្យាយាមស្វែងរកដោយពេញកំឡាំង បានសម្រេចផលដូចបំណង" ។

នៅវេលាគ្រានោះ ព្រះអង្គទ្រង់សំដែងអាការគោរពនៅទៀបព្រះបាទាក្សត្រីជាអគ្គមហេសី ទ្រង់ទតបំព្រះភក្ត្រព្រះនាងដែលកំពុងផ្ទំលក់មានព្រះអស្សុជលដោតព្រះភក្ត្រានៅឡើយ ដើម្បីទ្រង់លាចាកទៅ ហើយទ្រង់សន្សឹមៗ ប្រទក្សិណ ៣ ជុំក្រឡាព្រះបន្ទំដោយសេចក្ដីគោរព ហាក់ដូចជាវត្ថុជាទីគោរព ព្រះហត្ថាឱប ព្រះឱរាដ៏ញាប់ញ័រដួលជាខ្លាំងទ្រង់ព្រះបន្ទូលថា "តាំងពីថ្ងៃនេះតទៅ ខ្ញុំលែងផ្ទំក្នុងទីនេះទៀតហើយ" ។ ទ្រង់តាំងព្រះទ័យយាងចេញទៅដល់ ៣ ជង ប៉ុន្តែទ្រង់ត្រឡប់យាងចូលមកវិញដល់ ៣ ជង មិនបេះដាច់ស្រេច, លំអរព្រះនាងយសោធរាមានរូបឆើតឆាយណាស់, សេចក្ដីស្នេហារបស់ព្រះសិទ្ធត្ថបរមក្សត្រក៏ខ្លាំងក្លាណាស់ ។ រួចទ្រង់ទាញព្រះភួសាចេញពីព្រះកេសក្សត្រីទ្រង់ផាកព្រះអង្គចេញបើកព្រះសិរិយាឡើង ។

(មានត)

## និរយកថា

( ចាកនេមិរាជជាតក )

# មហា "ឌុម-ណាគ្រី"

ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ប្រៀបរៀង,

### ឧមត្ថុ · សុកតស្ស

ក្នុងនេមិរាជជាតកមានសេចក្តីដំណាលថា កាលដែលព្រះមុនិន្ទសម្ពុទ្ធជាម្ចាស់របស់យើងទាំងឡាយ បានសោយព្រះជាតិជាព្រះបាទនេមិរាជក្នុងក្រុងមិថិលា ក្សត្រាបានទ្រង់តាំងនៅក្នុងសីលនិងធម៌ដ៏ល្អ ទាំងទ្រង់ដឹកនាំក្រុមប្រជានិករពងបរិស័ទ ឲ្យប្រតិបត្តិប្រព្រឹត្តតាមព្រះអង្គផង, ប្រជារាស្ត្រទាសកម្មករពួកខ្លះ ដែលបានប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ កាលលះបង់អាយុជីវិតមុនព្រះអង្គទៅ ក៏បានទៅឧប្បត្តិកើតក្នុងកំណើតតាវតិំស្សទេវលោកជាច្រើនគ្នា ហើយបានពណ៌នាសរសើរគុណរបស់ព្រះអង្គក្នុងទីប្រជុំសមាគមទេវតាជាន់តាវតិំស្សរឿយ ៗ រហូតដល់ព្រះឥន្ទ្រកោសិយ ទ្រង់មានព្រះហឫទ័យចង់ទស្សនានិងទ្រង់ត្រូវការប្រាថ្នាស្តាប់ធម៌របស់ព្រះបាទនេមិរាជ ទើបទ្រង់មានទេវបញ្ជាបង្គាប់ប្រាប់ប្រើឲ្យមាតលីទេពសារថីនាំយកវេជយន្តរថ ចុះមកអញ្ជើញព្រះបាទនេមិរាជឲ្យស្តេចយាងទៅតាវតិំស្ស ។

ក្នុងខណៈ ដែលព្រះបាទនេមិរាជគង់លើយន្តរថ យាត្រាចេញចាកព្រះនគរទៅនោះ ទ្រង់មានព្រះរាជបំណងចង់ទស្សនាការស្ថាននរក ទើបត្រាស់ឲ្យមាតលីទេពសារថី បែររថចុះទៅផ្លូវបាតាល ដំណាលសំដែងរឿងនរកថ្វាយព្រះអង្គឲ្យទ្រង់ជ្រាប តាមសមគួរដល់សេចក្ដីមានប្រាកដក្នុងគម្ពីរដូចតទៅនេះ:

១ – **វេតរណីនទីនរក**: នរកស្ទឹងបន្លាផ្ដៅ (អធិប្បាយរួចហើយ[១])

២ – **សុនខនរក**: នរកសុនខ គឺនរកដែលពេញទៅដោយឆ្កែផ្សេងៗ មានគាថាសំគាល់ថា:

**សាមា ច សោណា សពលា ច គិជ្ឈា**
**កាកោលសង្ឃា ច អទេន្តិ ភេរវា ។**

ប្រែថា “ក្នុងនរកនេះ ពេញទៅដោយឆ្កែផ្សេងៗ ក្រហមខ្លះ ពពាលខ្លះ មានទាំងហ្វូងក្អែកគកដក់ ដែលមានខ្លួនធំៗ គួរខ្លាច” ។

កំណាយសេចក្ដីតាមអដ្ឋកថាថា:

ឆ្កែទាំងនោះ មានខ្លួនធំៗ ប៉ុនដំរីសារ សម្រាប់ខាំត្របាក់ពួកសត្វនរក ទីឯពួកសត្វក្នុងនរកនេះ មានរាងកាយកំពស់ ៣ គាវុត គឺ ៣០០ សិន, កាលពួកឆ្កែដេញទាន់ហើយ ក៏ត្របាក់ខាំឲ្យដួលចុះលើ

---

(១) មើលកម្ពុជសុរិយា ឆ្នាំ ១៩៤៨, លេខ ៧ ទំព័រ ៧៦៤ ។

ផែនដែកក្រហម យកជើងមុខទាំងពីរឡើងជាន់បំដើមទ្រូង ខាំត្របាក់សាច់ស៊ីទាល់តែអស់ នៅសេសសល់តែឆ្អឹង ។ ពួកត្មាតតាដក់សុទ្ធសឹងតែមានខ្លួនធំ ៗ ប៉ុនផ្ទះរទេះ មានចំពុះជាដែក តែងចឹកហែកស៊ីសត្វក្នុងនរកនេះ ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ លោកសំដែងទុកត្រឹមពីរយ៉ាង គឺ សេចក្ដីកំណាញ់នឹងការជេរស្ដីសមណព្រាហ្មណ៍ មានគាថាបញ្ជាក់ពន្យល់ទុកមកថា

យេ កេចិមេ មច្ឆរិនោ កទរិយា
បរិភាសកា សមណព្រាហ្មណានំ
ហឹសេន្តិ រោសេន្តិ ករុទាបធម្មា
តេ លុទ្ធកម្មា បសវេត្វ បាបំ
តេ មេ ជនេ កាកោលសង្ឃា អនេន្តិ ។

ប្រែថា បុគ្គលណាមានសេចក្ដីកំណាញ់នឹងហាមប្រាមគេមិនឲ្យធ្វើទាន នឹងជេរស្ដីបៀតបៀនគំរាមគំរេះសមណព្រាហ្មណ៍ បុគ្គលពួកនោះឈ្មោះថាធ្វើកម្មដ៏អាក្រក់ត្រូវធ្លាក់នរកនេះ ត្រូវពួកក្អែកត្មាតនឹងតាដក់ចឹកពាំងកាយ ។

៣ – អយបឋវីនរកា: នរកផែនដែកក្រហម គឺនរកដែលមានផែនដីជាផែនដែកក្រហមប្រមាណ ៩ យោជន៍ ពួកសត្វនរកនេះ

ត្រូវពួកនាយនិរយបាលពាយដោយអន្ទង់ដែកក្រហមចុះដើមគ្រោត ឲ្យដួលចុះ ហើយសំពង់ដោយញញួរដែកថែមទៀត រហូតដល់បែកល្អិតល្អន់ខ្ទេចខ្ទីមានគាថានិពន្ធថា

សញ្ជោតិភូតា បឋវឹ កមន្តិ
តត្តេហិ ខណ្ឌេហិ ច បោថយន្តិ ។

ប្រែថា ពពួកសត្វក្នុងនរកនេះ ជាអ្នកមានរាងកាយអណ្តែតឡើង ដើរទៅតាមផែនដី ត្រូវពួកនាយនិរយបាលសំពង់ដោយញញួរដ៏ក្តៅ ៗ

បាបកម្ម ដែលនាំឲ្យធ្លាក់នរកនេះ លោកពោលទុកត្រឹមការបៀតបៀនទឹងគ្រមាមគ្រមោះ មានគាថាសំអាងថា

យេ ជីវលោកស្មឹ សុបាបធម្មិនោ
នរញ្ច នារិញ្ច អបាបធម្មំ
ហឹសេន្តិ រោសេន្តិ សុបាបធម្មា
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា ខន្ធហតា សយន្តិ ។

ប្រែថា ជនណាក្នុងជីវលោកនេះ ជាអ្នកមានចិត្តអាក្រក់បៀតបៀន ត្រគោះគំរាមគំពោះដល់ស្ត្រីជនជាតិប្រុសស្រី ដែលមិនមានសេចក្តីខុស ជនដែលធ្វើកម្មដ៏អាក្រក់ទាំងនោះ លុះធ្វើសេចក្តីអាក្រក់ហើយ រមែងត្រូវប្រហារដោយញញួរដែក ។

៦ – អង្គារកាសុនរក : នរករងើកភ្លើង គឺនរករណ្ដៅរងើកភ្លើង ក្នុងនរកនេះពួកសត្វនរកត្រូវនាយនិរយបាលដេញវាយដោយញញួរដែកក្រហមក្ដៅ ឲ្យចុះទៅក្នុងរណ្ដៅរងើកភ្លើង ពួកសត្វនរកធ្លាក់ទៅក្នុងរណ្ដៅរងើកភ្លើងត្រឹមចង្កេះ ចំណែកពួកនាយនិរយបាល បានយកកន្ត្រងដែកធំៗ ដួសផងរងើកភ្លើងដែកក្រហមចាក់គរបន្ថែមលើក្បាលទៀត សត្វនរកទាំងនោះ កាលមិនអាចអត់ទ្រាំកំដៅបាន ក៏នាំគ្នាយំអន្ទះអន្ទែងខ្លោចផ្សា ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ លោកពោលទុកត្រឹមតែម្យ៉ាង មានគាថានិពន្ធថា

យេ កេចិ បូគាយ ធនស្ស ហេតុ
សក្ខឹ ការិត្វា ឥណំ ជា យន្តិ
តេ ជាបយិត្វា ជនតំ ជនិន្ទ
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា អង្គារកាសុំ ផុសន្តិ ។

ប្រែថា ជនណា ដើរឆបោករៃឃោសនាទ្រព្យរបស់អ្នកស្រុកមកបរិភោគដោយអាងថារៃទៅសាងថាវរវត្ថុ ឬបូជាព្រះពុទ្ធព្រះធម៌ព្រះសង្ឃ កាលបុគ្គលនោះស្លាប់ហើយរមែងធ្លាក់នរករងើកភ្លើង ។

៥ – លោហកុម្ភីនរក : នរកខ្ទះទង់ដែង (អធិប្បាយរួចហើយ (១)) ។

៦ – អយោគុឌនរក : នរកទឹកដែកក្រហម ក្នុងនរកនេះ ពួកនាយនិរយបាល យកខ្សែដែកដែលឆេះជាអណ្ដាតភ្លើងចងសត្វនរកទាំងឡាយទាញក្រោកឲ្យដួលចុះ ហើយតែមូលកឲ្យដាច់ទៅ ដូចមូលកចាបមួកមាន់ហើយបោះចុះទៅក្នុងទឹកក្ដៅ មានគាថាពន្យល់ថា

លុញ្ចន្តិ គីវំ អថ វេឋយិត្វា

ឧណ្ហោទកស្មឹ បកិលេទយិត្វា ។

ប្រែថា ពួកនាយនិរយបាលចងកសត្វនរកហើយមូលឲ្យដាច់ហើយបោះចុះទៅក្នុងទឹកក្ដៅ ។

ក្នុងអដ្ឋកថាថា សត្វក្នុងនរកនេះ មានខ្លួនកំពស់ ៣០០ សិនកាលត្រូវនាយនិរយបាលមូលកដាច់ហើយ ក៏មានកដទៃទៀតកើតឡើងជំនួសសោយទុក្ខតទៅ ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់អ្នកធ្វើបាបជាព្រានសត្វស្លាប មានគាថាសាធកៈថា

យេ ជីវលោកស្មឹ សុបាបធម្មិនោ

បក្ខី គហេត្វាន វិហេឋយន្តិ

---

១ មើលកម្ពុជសុរិយាលេខ ៩ ឆ្នាំ ១៩៦៦ ទំព័រ ៦១៣ ។

តេ ហោចយិត្វា សកុណំ ជធិទ្ធ
តេ លុទ្ទកម្មា បសវេត្វា ភាបំ
តេមេ ជនា លុត្តរិសា សយន្តិ ។

ប្រែថា មនុស្សមានចិត្តអាក្រក់ឯណា ក្នុងជីវលោកនេះ បៀតបៀនសត្វស្លាប់ទាំងឡាយ មនុស្សដែលមានចិត្តអាក្រក់ទាំងនោះ រមែងត្រូវមួលក (ឲ្យដាច់) ។

**៧– ថុសនរក:** នរកអង្កាម ក្នុងនរកនេះជាស្ទឹងមួយដែលមានទឹកថ្លាពេញប្រៀប កាលពួកសត្វនរកត្រូវសេចក្តីក្តៅដោយអណ្តាតភ្លើងក្នុងខណៈដែលទៅលើផែនដែកក្រហម, លុះឃើញស្ទឹងនោះ ក៏ចូលចិត្តថានឹងបានផឹកសប្បាយ តែកាលលោតចុះទៅហើយផឹកទឹកនោះ ចូលទៅដល់ក្នុងពោះ ទឹកនោះក៏ក្លាយជាអង្កាមដ៏ក្តៅ ឆេះពោះវៀនដាច់ជាកំណាត់ៗ ហើយហូរធ្លាក់ចុះទៅតាមផ្លូវក្រោម មានគាថាបញ្ជាក់ថា:

ពហុទកតោយា អនិមិត្តកូលា
នទី អយំ សន្ទតិ សុបតិត្ថា
ឃម្មាភិតត្តា មនុជា បិវន្តិ ។

ប្រែថា ស្ទឹងនេះ ពេញទៅដោយទឹក មានច្រាំងមិនជ្រៅ មានកំពង់ល្អ ពួកសត្វទាំងឡាយ ដែលត្រូវសេចក្តីក្តៅគ្របសង្កត់ហើយរមែងផឹកទឹកក្នុងស្ទឹងនោះ ទឹកដែលផឹកទៅហើយ រមែងក្លាយជាអង្កាម ។

កម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការយកស្រូវស្អកឬអង្កាមបន្ទុំ (ចេកបាវការុង) ធ្វើជាអង្ករលក់ មានគាថាជាបទដ្ឋានថា

យេ សុទ្ធធញ្ញំ បលាសេន មិស្សំ
អសុទ្ធកម្មា កយិនោ ទទន្តិ
ឃម្មាភិតត្តាន បិបាសិតានំ
បិវតំ តេសំ ភុសំ ហោតិ បានំ ។

ប្រែថា មនុស្សមានចិត្តមិនបរិសុទ្ធពួកណា បានលាយអង្ករដែលល្អស្អាតដោយអង្កាម លក់ឲ្យអ្នកដទៃ មនុស្សពួកនោះ គ្រាត្រូវសេចក្តីក្តៅគ្របសង្កត់ហើយ មានសម្រេកស្រេកទឹក, ទឹកដែលគេផឹកចូលទៅ ក៏ក្លាយជាអង្កាម ។

៨ – អយសូលនរក : នរកបម្រង លោកសំដែងទុកថា មានពួកនាយនិរយបាលចាំចាក់ម្ជុលជំនីរសត្វនរកដោយអាវុធផ្សេងៗ មានបម្រងដែកជាដើម រាងកាយសត្វនរកទាំងនោះ ធ្លុះជាប់ជាកំណាត់តូច កំណាត់ធំ មានគាថាសំដែងទុកថា

ឧសូហិ សត្តីភិ ច តោមរេហិ
ឧភយានិ បស្សានិ តុទន្តិ កន្ទតំ

ប្រែថា នាយនិរយបាលទាំងឡាយ រមែងចាក់ម្ជុលជំនីរទាំងពីររបស់ពួកសត្វនរកដែលគ្រាំគ្រានៅ ដោយបម្រងនឹងលំពែងនឹងដែកស្រួច ។

កម្មដែលនាំបណ្ដាលឲ្យធ្លាក់នរកនេះ លោកពោលទុកត្រឹមពីរយ៉ាង គឺការលួច ៣ យ៉ាងមានគាថាសំអាងថា

យេ ជីវលោកស្មឹ អសាធុកម្មិនោ
អទិន្នមាទាយ ករោន្តិ ជីវិកំ
ធញ្ញំ ធនំ រជតំ ជាតរូបំ
អជេឡកញ្ចាបិ បសុំ មហឹសំ
តេ លុទ្ទកម្មា បសវេត្វ បាបំ
ឃោរេ ជនា សត្តុហាតា សយន្តិ ។

ប្រែថា ជនពួកណា ដែលជាអ្នកបួលចិត្តប្រព្រឹត្តធ្វើអំពើមិនល្អក្នុងជីវលោកនេះ បានលួចយកស្រូវអង្ករ, ទ្រព្យមាសប្រាក់, ពពែក្របី របស់អ្នកដទៃមកចិញ្ចឹមជីវិត ពួកអ្នកដែលធ្វើអំពើមិនល្អទាំងនោះ លុះធ្វើសេចក្ដីអាក្រក់ហើយ រមែងត្រូវបាក់ដោយលំពែង ។

៤– សញ្ញាតិនរក :– នរកអាវុធដែកក្រហម លោកសំដែងទុកថា មានពួកនាយនិរយបាល ចងកសត្វនរកដោយខ្សែដែកដ៏ធំ ដែលឆេះជាអណ្ដាតភ្លើង ទាញអូសទៅតាមផែនដីដែកដ៏ឆេះសន្ធោសន្ធៅ ត្រាសត្វនរកដួលចុះហើយ ក៏កាប់យកដោយអាវុធផ្សេងៗ មានគាថាបញ្ជាក់ថា

គីកាយ ពន្ធា កិស្សមេ ឬនេកោ
អញ្ញោ វិកន្តា វិលកតា សយន្តិ ។

ប្រែថា ពួកសត្វនរកក្នុងនរកនេះ រមែងមាននាយនិរយបាលយកខ្សែបន្ទាត់សំឡេះសាច់ចេញជាកង់ទុកដូចសំឡេះសត្វព្រៃ ។

ក្នុងអដ្ឋកថាថា សត្វក្នុងនរកនេះត្រូវនាយនិរយបាលសំឡេះសាច់កន្ទុកជាកង់ៗ ។

កម្មដែលនាំឲ្យមានទំហុស បណ្តាលឲ្យធ្លាក់ចុះនរកនេះ លោកថាទុកតែត្រឹមការសំឡាប់សត្វលក់ មានគាថាជាបទដ្ឋានថា

ឱរព្ភិកា សូករិកា ច មច្ឆិកា

បសុំ មហិសញ្ច អជេឡកញ្ច

ហន្ត្វាន សូណេសុ បសារយឹសុ

តេ លុទ្ធកម្មា បសវេត្វ ចាបំ

តេមេ ជនា វិលកតា សយន្តិ ។

ប្រែថា បុគ្គលពួកណាសម្លាប់ពពែ ជ្រូកត្រីគោក្របីហើយនាំទៅលក់ទីផ្សារ បុគ្គលពួកនោះ រមែងត្រូវនាយនិរយបាលសំឡេះសាច់ចេញទុកជាកង់ៗ ។

១០ គូថនរកៈ- នរកដុំលាមក (អធិប្បាយរួចហើយ)[១]

១១ លោហិតបុព្វនរកៈ- នរកឈាមនិងខ្ទុះ ពួកសត្វក្នុងនរកនេះបានផឹកស៊ីតែឈាមនិងខ្ទុះ មានគាថានិពន្ធថា (មាន៩)

១ មើលកម្ពុជសុរិយាលេខ ៩ ឆ្នាំ ១៩៤៧ ទំព័រ ៦៩២ ។

# អំពីតាំងចៅអធិការថ្មី

( តមក )

---

សញ្ញាប័ត្រលេខ ៣៩៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មុំ-រស់ នាមឆាយា ធម្មសរ កើតឆ្នាំជូត អាយុ ៦១ វស្សា ៤០ ជាចៅអធិការ វត្តស្មោង ឃុំស្មោង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ រស់-ហ៊ឹង នាមឆាយា ធម្មសរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៧ ជាចៅអធិការ វត្តដងក្តោង ឃុំក្រចៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៩៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់-ជិន នាមឆាយា ជិនត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តស្វាយអង្គ ឃុំជ្រៃ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គួរ-ចក់ នាមឆាយា សុវណ្ណជោត កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ែម-ដួង នាមឆាយា គន្ធសរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តក្រចៅ ឃុំក្រចៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូទៀវ-ផន នាមធាយា ធម្មប្បញ្ញោ កើតឆ្នាំជូត អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូម៉ម-មួង នាមធាយា ចន្ទត្ថេរ កើតឆ្នាំមមី អាយុ ៥៥ វស្សា ៣៥ ជាគ្រូសូត្រស្តាំ វត្តសង្កែ ឃុំសាំងឃ្វាង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូគិម-សែម នាមធាយា ធម្មកេសរ កើតឆ្នាំរកា អាយុ ៤០ វស្សា ២០ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូវង នេត្រ នាមធាយា គន្ធជោត កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្តដងក្តោង ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៤០៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូគួរ-សាន នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំជូត អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤០៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូយី-ញ៉ាង នាមធាយា សុវណ្ណជោត កើតឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តមុនីរតនៈ ឃុំសាំងឃ្វាង ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៦០៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុង-សន នាមងារ សុវណ្ណប្បញ្ញោ កើតឆ្នាំឆ្លូវ អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦០៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-តេង នាមងារ សុវណ្ណជោត កើតឆ្នាំ ១៨៩០ អាយុ ៥៨ វស្សា ២៦ ជាចៅអធិការ វត្តបន្ទាយជ័យ ឃុំកំពង់ត្រាស ស្រុកក្រូចឆ្មារ កំពង់ចាម ។

សញ្ញាប័ត្រលេខ ៦១០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ឹម-ហួន នាមងារ ជោតត្ថេរ កើតឆ្នាំមមី អាយុ ៣១ វស្សា ១០ ជាចៅអធិការ វត្តស្អាង ឃុំទីពោធិ៍ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៦១១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ចេង នាមងារ គន្ធវិនយ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១០ ជាចៅអធិការ វត្តពោធិ៍ពិសី ឃុំដាច ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៦១២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពេជ្រ-សួន នាមងារ សុវណ្ណប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ៣២ ជាចៅអធិការ វត្តស្វាយទាប ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤១៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-អ៊ុច នាមធាយា ឥន្ទត្ថេរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៧ ជាចៅអធិការ វត្តអង្គខ្នាប់ ឃុំព្រៃញាត ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤១៩ ចុះថ្ងៃសៅរ៍ ៥ រោចខែកត្តិកឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ប្រាក់-ឡុម នាមធាយា ឥន្ទជោត កើតឆ្នាំច អាយុ ៥១ វស្សា ២៩ ជាចៅអធិការ វត្តតន្ទលីបូណ៌ វត្តកំពង់អំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ៤២០ ចុះថ្ងៃចន្ទ ១៣ រោចខែកត្តិកឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ព្រំ-មាស នាមធាយា ឥន្ទត្ថេរ កើតឆ្នាំមមី អាយុ ៥៥ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ ឃុំពោធិ៍អង្គ្រង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤២១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សួស មាស នាមធាយា មណ្ឌត្ថេរ កើតឆ្នាំរក អាយុ ២៩ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាបត្រលេខ ៤២២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គុយ-គុច នាមធាយា រតនត្ថេរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៧ ជាគ្រូសូត្រស្តាំ វត្តអង្គវៀល ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤២៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពេជ្រ-កៀក នាមធាយា សុមនត្ថេរ អាយុ ៣៧ វស្សា ១៧ ជាគ្រូសូត្រធ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈុន-ធន នាមធាយា គន្ធជោត កើតឆ្នាំច អាយុ ៥១ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តព្រះនិព្វាន ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤២៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កើត-សៀង នាមធាយា សុមនត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តធុង ឃុំធុង ស្រុកខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឯក-បាន នាមធាយា ចន្ទត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រធ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ-ព្រឿង នាមធាយា ព្រហ្មសរ កើតឆ្នាំថោះ អាយុ ៣៤ វស្សា ៦ ជាគ្រូសូត្រធ្វេង វត្តខ្វែក ឃុំទឹកល្អក់ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-សៀក នាមធាយា សុន្ទរត្ថេរ កើតឆ្នាំច អាយុ ៣៩ វស្សា ១២ ជាគ្រូសូត្រស្តាំ វត្តឧត្តមគិរី ឃុំស្នក្រពើ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤២៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពៅ-ផូរ នាមធាយា ចន្ទត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៩ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ាម-ឈន នាមធាយា ចន្ទត្ថេរ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តកាត់កុក ឃុំផុង ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន-សាន នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សម-ដាំ នាមធាយា ព្រហ្មត្ថេរ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្តក្រាំងក្រូច ឃុំដើមរុក ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ស៊ុម នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំឆ្លូវ អាយុ ៤៤ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្តទួលក្រាស ឃុំផុង-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ឡុង នាមធាយា ធម្មប្បញ្ញោ កើតឆ្នាំជូត អាយុ ៦១ វស្សា ២៦ ជាគ្រូសូត្រស្តាំ វត្តអង្គព្រះស្រី ឃុំព្រៃញាក ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៣៥ ចុះកាលបរិច្ឆេទដដែល នាមឆាយា ចន្ទត្ថេរ កើតឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ១៦ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ៗ

សញ្ញាប័ត្រលេខ ៤៣៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អាន-រុន នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តអង្គរោង ឃុំព្រៃញាត ស្រុក-ខេត្តដដែល ៗ

សញ្ញាប័ត្រលេខ ៤៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន-អ៊ុន នាមឆាយា ឥន្ទជោត កើតឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តថ្លល់រកា ឃុំបសែត ស្រុក-ខេត្តដដែល ៗ

សញ្ញាប័ត្រលេខ ៤៣៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន យ៉ែម នាមឆាយា សុធម្មប្បញ្ញោ កើតឆ្នាំមមែ អាយុ ៣០ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ៗ

សញ្ញាប័ត្រលេខ ៤៣៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គីរ-ពេជ្រ នាមឆាយា ធម្មជោត កើតឆ្នាំមមី អាយុ ៤៣ វស្សា ២២ ជាគ្រូសូត្រស្តាំ វត្តបសែត ឃុំបសែត ស្រុក-ខេត្តដដែល ៗ

សញ្ញាប័ត្រលេខ ៤៤០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ-ណៃ នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំមមី អាយុ ៤៣ វស្សា ១១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ៗ

សញ្ញាប័ត្រលេខ ៤៤១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែ-សឿន នាមជាយា តន្ទត្ថេរ កើតឆ្នាំមមី អាយុ ៤៣ វស្សា ២១ ជាគ្រូសូត្រស្តាំ វត្តអង្គសំទង ឃុំស្នំក្រពើ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃួន-នាង នាមជាយា នន្ទត្ថេរ កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ណុប-យ៉ែម នាមជាយា គន្ធជោត កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តកំពង់ថ្ម ឃុំនិទាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួង-សាផន នាមជាយា គន្ធត្ថេរ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តស្វាយទាប ឃុំស្នំក្រពើ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ូ-ទីវ នាមជាយា ឧន្ទត្ថេរ កើតឆ្នាំខាល អាយុ ២៣ វស្សា ១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួង-កឿង នាមជាយា ហិន្ទត្ថេរ កើតឆ្នាំរោង អាយុ ៤៥ វស្សា ១២ ជាគ្រូសូត្រស្តាំ វត្តអង្គព្រះពាន ឃុំកល ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ក់-ឆិត នាមធាយា ព្រហ្មជោត កើតឆ្នាំឆ្លូវ អាយុ ៥៨ វស្សា ៣៨ ជាគ្រូសូត្រស្តាំ វត្តត្រពាំងក្រពើ ឃុំព្រះនិព្វាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ វ៉ែន-ពូក នាមធាយា ពុទ្ធគោ្គ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ បាប-អ៊ិម នាមធាយា សុធម្មគោ្គ កើតឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តអន្លង់ទង ឃុំនិគាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ដែក-ហត់ នាមធាយា សុធម្មគោ្គ កើតឆ្នាំឆ្លូវ អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឯក-សួន នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ល្វា ឃុំស្វាយរំពា ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ុប-អ៊ូច នាមធាយា គន្ធជោត កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៣ ចុះកាលបរិច្ឆេទដដែល តាំងលោកស្រី ម៉ុក-ជិម នាមធាយា ធម្មវិជ្ជោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តអង្គទន្លាប់ ឃុំព្រៃញាត ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤៥៤ ចុះកាលបរិច្ឆេទដដែល តាំងលោកស្រី សួស-ប៉ាត់ នាមធាយា ធម្មកេសរ កើតឆ្នាំឆ្លូវ អាយុ ២៤ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៥ ចុះកាលបរិច្ឆេទដដែល តាំងលោកស្រី គន់-សួន នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំរកា អាយុ ៥២ វស្សា ៣១ ជាគ្រូសូត្រស្តាំ វត្តអន្ទង់គគីរ ឃុំព្រះនិព្វាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៦ ចុះកាលបរិច្ឆេទដដែល តាំងលោកស្រី ម៉ី-សាប៊ុន នាមធាយា ព្រហ្មប្បញ្ញោ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៧ ចុះកាលបរិច្ឆេទដដែល តាំងលោកស្រី ឯក-វ៉ែន នាមធាយា វិនកេសរ កើតឆ្នាំ ១៩១២ អាយុ ៣៦ វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្តព្រៃទទឹង ឃុំព្រះនិព្វាន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៥៨ ចុះកាលបរិច្ឆេទដដែល តាំងលោកស្រី ណាន-វឿន នាមធាយា សិរិមេត្តោ កើតឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។ (មានត)

កំណត់

# ស្នើអំពីរឿងស្ថាបនាវិទ្យាស្ថានមួយ

## សម្រាប់សិក្សាភាសាឥណ្ឌា - ខ្មែរ នៅភ្នំពេញ

លោកភិយ - ប៊ុក ក្រុមការក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែចេញពីបារាំងមកខ្មែរ

ការសិក្សាភាសាឥណ្ឌាទូទៅ ជាកិច្ចមានប្រយោជន៍ និងសារៈសំខាន់ចំពោះប្រទេសកម្ពុជា ដូចគ្នានឹងការសិក្សាភាសាក្រិក - ឡាតាំង ដែលគេដំកល់ទុកសម្រាប់និស្សិតរៀនសូត្រ នៅសាលារៀនក្នុងប្រទេសបារាំង, ការចេះដឹងនូវភាសាសំស្ក្រឹតនិងបាលី ព្រមទាំងអារ្យធម៌ឥណ្ឌា ដែលទាក់ទងដោយអារ្យធម៌នៃប្រទេសជិតខាង ខាងផ្លូវប្រវត្តិសាស្ត្រ, ជាកិច្ចគួរបំពេញ ដើម្បីស្រាវជ្រាវនូវទំនៀមទម្លាប់ប្រពៃណីបុរាណខ្មែរ ដែលមានអត្ថដ៏គម្ភីរភាព ហើយនិងងាយស្វែងរកនូវវត្ថុធាតុ ដែលជាបុព្វហេតុនៃទំនៀមទម្លាប់នោះ ៗ

ព្រោះហេតុដូច្នេះ ត្រូវតែបណ្ឌិតខ្មែរក្នុងកាលជាអនាគតប្រមូលគ្នាឲ្យបានច្រើនជាងមុន ដើម្បីនឹងចូលទៅសន្ទនាការអំពីរឿងបូព៌ាវិទ្យានិយមរវាងប្រជាជាតិ ( l'orientalisme international ) មានការសិក្សាខាងភាសាឥណ្ឌាជាកិច្ចត្រូវស្វែងរកដោយពិសេស, បណ្ឌិតទាំងនោះ ក្នុងពេលសន្ទនាការរឿងរ៉ាវក្នុងសាកលលោក អាចឆ្លៀតឱកាសរកផល

ប្រយោជន៍ក្នុងរឿងនោះ ដាក់បញ្ចូលមកក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរបាន លោកអ្នកប្រាជ្ញទាំងប៉ុន្មាន អាចចូលទៅប្រស្រ័យចំពោះកិច្ចការខាងសាលា បារាំងបូព៌ាប្រទេសដែលជាតំណាងក្នុងការស្វែងរកបូព៌ាវិទ្យានិយមជាសាធារណៈ អាចរៀបចំនូវក្រមសញ្ញាតិខ្មែរ ខាងសិលាចារិកបុរាណវិទ្យា នឹងស្ថាបនានូវមធ្យមសិក្សានិស្សិតខ្មែរ ដែលត្រូវយកសាស្ត្រាចារ្យមានសមត្ថភាព ខាងភាសាគណ្ឋៀមកបង្រៀនបានដោយឆាប់រហ័ស ។

ដើម្បីនឹងឧបត្ថម្ភបណ្ឌិតខ្មែរ ដែលពេញចិត្តក្នុងការស្វែងរករឿងនេះ, ប្រទេសបារាំងសែសគួរស្នើចំពោះកម្ពុជរដ្ឋអំពីគ្រោង ការស្ថាបនាវិជ្ជាស្ថាននៅក្រុងភ្នំពេញ សម្រាប់សិក្សាឧត្តមវិជ្ជាដែលគេអាចយកគោលការសិក្សាកិច្ចស្វែងរកភាសាគណ្ឋៀនៃសាលាឧត្តមវិជ្ជានៅប៉ារីសមកបញ្ចូលផងបាន ។

ការសិក្សានេះ ត្រូវបើកសិទ្ធិឲ្យជនគ្រប់រូបចូលទៅរៀនបានដោយសេរី ឥតមានរើសមុខ, គុណបំណាច់ដែលរៀនក្នុងសាលានោះ ត្រូវបានសញ្ញាបត្រមួយ ដែលនឹងប្រគល់ឲ្យបាន លុះត្រាតែបេក្ខជននោះបានធ្វើកិច្ចការអ្វីមួយដ៏គាប់ប្រសើរ ហើយបានចូលទៅរៀនបណ្ដោះអាសន្ននៅសាលាក្នុងរយៈវេលា ២ ឆ្នាំ ដោយទទួលសេចក្ដីយល់ព្រមពី

គណៈកម្មការសាលា ដែលបានយករូបបេក្ខជនទៅបង្ហាញចំពោះចាងហ្វាងសាលានោះ ។

នៅភ្នំពេញ ការសិក្សានេះដែលនឹងធ្វើបាន លុះត្រាតែចាត់ចាងហ្វាងនៃការសិក្សាមួយនាក់ពីប៉ារីស ក្នុងរយៈវេលា ៦ ខែក្នុង ១ ឆ្នាំ, លេខាធិការដ្ឋានជាអចិន្ត្រៃ នៃវិជ្ជាស្ថានឧត្តមសិក្សានេះ ត្រូវមានសមាជិកខាងសាលាបូព៌ាប្រទេសម្នាក់មកកាន់ការនៅភ្នំពេញ បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ សម្រាប់ជាមន្ទីរធ្វើការផ្សេង ៗ នៃក្រមនេះ, ប្រាក់ចំណាយក្នុងរឿងនេះ ត្រូវប្រទេសបារាំងសែស នឹងប្រទេសកម្ពុជា ទទួលបន្ទុកជួយគ្នាទៅវិញទៅមក, ប្រាក់បៀវត្សនៃចាងហ្វាងសាលា ត្រូវប្រទេសបារាំងសែសចេញឲ្យ ចំណែកខាងប្រទេសកម្ពុជា ត្រូវចេញតែខាងប្រាក់ចំណាយសោហ៊ុយសំណាក់អាស្រ័យក្នុងទីនេះ នឹងថ្លៃយានជំនិះ ។

ចំពោះឆ្នាំ ១៩៥០ ប្រាក់ចំណាយក្នុងរឿងនេះ តាមសេចក្ដីស្នាននៃរាជរដ្ឋាភិបាលខ្មែរប្រហែលជា ៦ - ៧ ម៉ឺនរៀល ។